៨- ភិក្ខុនីណាមួយ មានតម្រេកហើយត្រេកអរនឹងការចាប់ដៃក្តី ត្រេកអរនឹងការចាប់ជាយសង្ឃាដីក្តី របស់បុរសបុគ្គលដែលមានតម្រេក ឈរជាមួយក្តី ចរចាជាមួយក្តី ទៅកាន់ទីសង្កេតក្តី ត្រេកអរនឹងប្រុសដើរចូលមកជិតក្តី ចូលទៅកាន់ ទីកំបាំងក្តី ពិចារណាកាយដើម្បីអសទ្ធម្មនោះក្តី ដើម្បីនឹងសេពមេថុនធម្មនុ៎ះក្តី ភិក្ខុនីនេះ ត្រូវអាបត្តិបារាជិក ឈ្មោះអដ្ឋវត្ថុកា (ព្រោះប្រកបដោយវត្ថុ៨) ជាស្ត្រីមិនមានសង្វាស ។

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិឈ្មោះបារាជិកទាំង ៨ ខ្ញុំព្រះករុណាបានសម្តែងរួចហើយ ។ បណ្តាអាបត្តិទាំង ៨ នុ៎ះ ភិក្ខុនីណាត្រូវអាបត្តិបារាជិកណាមួយហើយ ភិក្ខុនីនោះ មិនបានទូវការនៅរួមជាមួយនឹងភិក្ខុនីទាំងឡាយឡើយ (ព្រោះ)ខ្លួនត្រូវអាបត្តិបារាជិករកសង្វាសគ្មាន កាលពីមុនយ៉ាងណាមិញ លុះខាងក្រោយមក ភិក្ខុនីនោះ ក៏ជាបារាជិក រកសំវាសគ្មានយ៉ាងនោះដែរ ។ ខ្ញុំព្រះករុណាសូមសួរលោកម្ចាស់ទាំងឡាយ ក្នុងអាបត្តិបារាជិកទាំង ៨ នោះ លោកម្ចាស់ទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាលើកទី ២ ម្តងទៀត

៤០

# ភិក្ខុនីចាតិមោក្ខបាលី

កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

**បារាជិកុទ្ទេសោ និដ្ឋិតោ ។**

# ភិក្ខុនីបាតិមោក្ខ-ប្រែ

លោកម្ចាស់ទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាលើកទី ៣ ម្តងទៀត លោកម្ចាស់ទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? លោកម្ចាស់ ទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងបារាជិកទាំង ៨ នុ៎ះហើយ ព្រោះហេតុនោះ បានជាលោកម្ចាស់នៅស្ងៀម ។ ខ្ញុំព្រះករុណាសូមចាំទុកហេតុនេះដោយកិរិយានៅស្ងៀមនោះឯង ។

## ចប់ បារាជិកុទ្ទេស ។

# សង្ឃាទិសេសុទ្ទេសោ

ឥមេ ខោ បនយ្យាយោ សត្តរស សង្ឃាទិសេសា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១- យា បន ភិក្ខុនី ឧស្សុយ្យវាទិកា វិហរេយ្យ គហបតិនា វា គហបតិបុត្តេន វា ទាសេន វា កម្មករេន វា អន្តមសោ សមណាបរិព្វាជកេនាបិ អយំ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

២- យា បន ភិក្ខុនី ជានំ ចោរឹ វជ្ឈវិទិតំ អនបលោកេត្វា រាជានំ វា សង្ឃំ វា គណំ វា បូគំ វា សេណឹ វា អញ្ញត្រ កប្បា វុដ្ឋាបេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

៣- យា បន ភិក្ខុនី ឯកា វា គាមន្តរំ គច្ឆេយ្យ ឯកា វា នទីចារំ គច្ឆេយ្យ ឯកា វា រត្តឹ វិប្បវសេយ្យ ឯកា វា គណម្ហា ឱហីយេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

# សង្ឃាទិសេសុទ្ទេស

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិសង្ឃាទិសេសទាំង ១៧ នេះ មកកាន់ឧទ្ទេស ។

១- ភិក្ខុនីណាមួយ ជាអ្នកប្តឹងផ្តល់ពីគហបតីក្តី កូនគហបតីក្តី ខ្ញុំគេក្តី អ្នកធ្វើការងារក្តី ដោយហោចទៅសូម្បីតែសមណបរិព្វាជក ភិក្ខុនីនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

២- ភិក្ខុនីណាមួយ ដឹងថាស្រីជាចោរដែលគេដឹងច្បាស់ថាត្រូវសម្លាប់ហើយ មិនជម្រាបស្តេចក្តី (អ្នករាជការក្តី) សង្ឃក្តី គណៈក្តី ប្រជុំជនក្តី សេនាក្តី ហើយបំបួសស្រីនោះ វៀរលែងតែកប្ប (គឺមានសំបុត្រច្បាប់) ភិក្ខុនីនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

៣- ភិក្ខុនីណាមួយ ទៅកាន់ចន្លោះស្រុកតែម្នាក់ឯងក្តី ទៅកាន់ត្រើយស្ទឹងខាងនាយតែម្នាក់ឯងក្តី នៅប្រាសចាកគ្នាក្នុងវេលារាត្រីតែម្នាក់ឯងក្តី ឈប់ឃ្លាតអំពីពួកតែម្នាក់ឯងក្តី ភិក្ខុនីនេះឯង ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

៤២

# ភិក្ខុនីបាតិមោក្ខបាលី

៤- យា បន ភិក្ខុនី សមគ្គេន សង្ឃេន ឧក្ខិត្តំ ភិក្ខុនឹ ធម្មេន វិនយេន សត្ថុសាសនេន អនបលោកេត្វា ការកសង្ឃំ អនញ្ញាយ គណស្ស ឆន្ទំ ឱសារេយ្យ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

៥- យា បន ភិក្ខុនី អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

៦- យា បន ភិក្ខុនី ឯវំ វទេយ្យ កិន្តេ អយ្យេ ឯសោ បុរិសបុគ្គលោ ករិស្សតិ អវស្សុតោ វា អនវស្សុតោ វា យតោ ត្វំ អនវស្សុតា ឥង្ឃយ្យេ យន្តេ ឯសោ បុរិសបុគ្គលោ ទេតិ ខាទនីយំ វា ភោជនីយំ វា តំ ត្វំ សហត្ថា បដិគ្គហេត្វា ខាទ វា ភុញ្ជ វាតិ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

៧- យា បន ភិក្ខុនី សញ្ចរិត្តំ សមាបជ្ជេយ្យ ឥត្ថិយា វា បុរិសមតឹ បុរិសស្ស វា ឥត្ថីមតឹ ជាយត្តនេ វា ជារត្តនេ វា អន្តមសោ តំខណិកាយបិ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

# ភិក្ខុនីបាតិមោក្ខ-ប្រែ

៤- ភិក្ខុនីណាមួយ មិនបានប្រាប់ការកសង្ឃ មិនដឹងសេចក្ដីប្រាថ្នារបស់គណៈ ហើយសូត្របញ្ចូលភិក្ខុនីដែលសង្ឃព្រមព្រៀងគ្នា លើកវត្តតាមធម៌ តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា ភិក្ខុនីនេះក្ដី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្ដេញចេញចាកសង្ឃ ។

៥- ភិក្ខុនីណាមួយ មានតម្រេកទទួលយកខាទនីយក្ដី ភោជនីយក្ដី អំពីដៃបុរស-បុគ្គលដែលមានតម្រេកដែរ ដោយដៃនៃខ្លួន ហើយទំពាស៊ីក្ដី បរិភោគក្ដី ភិក្ខុនីនេះក្ដី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្ដេញចេញចាកសង្ឃ ។

៦- ភិក្ខុនីណាមួយ ពោលយ៉ាងនេះថា នៃលោកម្ចាស់ បុគ្គលប្រុសនេះទុកជាមានតម្រេកក្ដី មិនមានតម្រេកក្ដី នឹងធ្វើអ្វីដល់លោកបាន នៃលោកម្ចាស់ ណ្ហើយចុះ កាលណាបើលោកមិនមានតម្រេកទេ បើបុគ្គលប្រុសនោះឲ្យវត្ថុឯណា ជាខាទនីយក្ដី ជាភោជនីយក្ដីដល់លោក លោកចូរទទួលយកវត្ថុនោះដោយដៃខ្លួន ហើយទំពាស៊ី ឬបរិភោគចុះ ភិក្ខុនីនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្ដេញ-ចេញចាកសង្ឃ ។

៧- ភិក្ខុនីណាមួយ ប្រព្រឹត្តនិយាយដឹកនាំ ប្រាប់សេចក្ដីប្រាថ្នា របស់បុរសដល់ស្ត្រីក្ដី ប្រាប់សេចក្ដីប្រាថ្នារបស់ស្ត្រីដល់បុរសក្ដី ឲ្យបានគ្នាជាប្ដីប្រពន្ធ ឬជាសហាយស្មន់ ដោយហោចទៅសូម្បីប្រាប់ដល់ស្រីពេស្យា ភិក្ខុនីនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្ដេញចេញចាកសង្ឃ ។

# សង្ឃាទិសេសុទ្ទេសោ

៨- យា បន ភិក្ខុនី ភិក្ខុនឹ ទុដ្ឋា ទោសា អប្បតីតា អមូលកេន បារាជិកេន ធម្មេន អនុទ្ធំសេយ្យ អប្បេវ នាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ តតោ អបរេន សមយេន សមនុគ្គាហិយមានា វា អសមនុគ្គាហិយមានា វា អមូលកញ្ចេវ តំ អធិករណំ ហោតិ ភិក្ខុនី ច ទោសំ បតិដ្ឋាតិ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

៩- យា បន ភិក្ខុនី ភិក្ខុនឹ ទុដ្ឋា ទោសា អប្បតីតា អញ្ញភាគិយស្ស អធិករណស្ស កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ បារាជិកេន ធម្មេន អនុទ្ធំសេយ្យ អប្បេវ នាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យន្តិ តតោ អបរេន សមយេន សមនុគ្គាហិយមានា វា អសមនុគ្គាហិយមានា វា អញ្ញភាគិយញ្ចេវ តំ អធិករណំ ហោតិ កោចិ ទេសោ លេសមត្តោ ឧបាទិន្នោ ភិក្ខុនី ច ទោសំ បតិដ្ឋាតិ អយម្បិ ភិក្ខុនី បឋមាបត្តិកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

## សង្ឃាទិសេសុទ្ទេស

៨- ភិក្ខុនីណាមួយ ក្រោធខឹង ប្រទូស្ត អាក់អន់ចិត្ត ចោទកម្ចាត់ភិក្ខុនីផងគ្នា ដោយអាបត្តិបារាជិក មិនមានមូលហេតុ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ! អញនឹងញ៉ាំង ភិក្ខុនីនោះ ឲ្យឃ្លាតចាកព្រហ្មចរិយធម៌នេះបាន លុះដល់សម័យដទៃពីនោះមក ទោះមានគេសាកសួរក្តី ឥតមានគេសាកសួរក្តី បើអធិករណ៍នោះប្រាកដជាពុំមានមូលហេតុមែន ទាំងភិក្ខុនីក៏ប្តេជ្ញាទោសខ្លួនឯង ភិក្ខុនីនេះត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

៩- ភិក្ខុនីណាមួយ ក្រោធខឹង ប្រទូស្ត អាក់អន់ចិត្ត ប្រកាន់យកហេតុបន្តិចបន្តួចនៃអធិករណ៍ ដែលជារឿងដទៃមកជាគ្រឿងអាង ហើយចោទភិក្ខុនីដោយអាបត្តិបារាជិក ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ! អញនឹងញ៉ាំងភិក្ខុនីនោះឲ្យឃ្លាតចាកព្រហ្មចរិយធម៌នេះបាន លុះដល់សម័យដទៃពីនោះមក ទោះមានគេសាកសួរក្តី ឥតមានគេសាកសួរក្តី បើអធិករណ៍នោះ ជារឿងដទៃទេ ភិក្ខុនីប្រកាន់យកហេតុត្រឹមតែបន្តិចបន្តួច មកជាគ្រឿងអាង ទាំងភិក្ខុនីក៏ប្តេជ្ញាទោស ខ្លួនឯងផង ភិក្ខុនីនេះ ត្រូវអាបត្តិសង្ឃាទិសេស ជាបឋមាបត្តិក គួរបណ្តេញចេញចាកសង្ឃ ។

# ភិក្ខុនីបាតិមោក្ខបាលី

១០- យា បន ភិក្ខុនី កុបិតា អនត្តមនា ឯវំ វទេយ្យ ពុទ្ធំ បច្ចាចិក្ខាមិ ធម្មំ បច្ចាចិក្ខាមិ សង្ឃំ បច្ចាចិក្ខាមិ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមា វ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា នាយ្យេ[1] កុបិតា អនត្តមនា ឯវំ អវច ពុទ្ធំ បច្ចាចិក្ខាមិ ធម្មំ បច្ចាចិក្ខាមិ សង្ឃំ បច្ចាចិក្ខាមិ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមា វ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ ។ អភិរមយ្យេ ស្វាក្ខាតោ ធម្មោ ចរ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

---

(១) ក្នុងដីកា ថា មាយ្យេ ។

# ភិក្ខុនីបាតិមោក្ខ-ប្រែ

១០- ភិក្ខុនីណាមួយ ខឹងអាក់អន់ចិត្ត ហើយពោលយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាធីតាព្រះពុទ្ធជាសក្យៈ ភិក្ខុនីទាំងឡាយនេះ នឹងហៅថា សមណីដូចម្តេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យ ក្នុងសំណាក់សមណីទាំងឡាយនោះ ។ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយ និយាយយ៉ាងនេះថា នែលោកម្ចាស់ លោកកុំខឹងអាក់អន់ ហើយនិយាយយ៉ាងនេះថា ខ្ញុំលាព្រះពុទ្ធ ខ្ញុំលាព្រះធម៌ ខ្ញុំលាព្រះសង្ឃ ខ្ញុំលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាសក្យធីតា ភិក្ខុនីទាំងឡាយនេះ នឹងហៅថាជាសមណីដូចម្តេចបាន សូម្បីសមណីទាំងឡាយដទៃដែលមានសេចក្តីខ្មាស មានសេចក្តីរង្កៀសប្រាថ្នាការសិក្សាគង់មានខ្លះដែរ អញនឹងប្រព្រឹត្តព្រហ្មចារ្យ ក្នុងសំណាក់សមណីទាំងឡាយនោះដូចនេះឡើយ ។ នែលោកម្ចាស់ ចូរលោកត្រេកអរ (ព្រោះ) ធម៌ព្រះមានព្រះភាគសម្តែងល្អហើយចូរលោកប្រព្រឹត្តព្រហ្មចារ្យ ដើម្បីធ្វើនូវទីបំផុតទុក្ខ ដោយប្រពៃចុះ ឯភិក្ខុនីនោះ កាលបើត្រូវភិក្ខុនីទាំងឡាយ ពោលយ៉ាងនេះ នៅប្រកាន់យ៉ាងនោះដដែល ត្រូវភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្ម ចំពោះភិក្ខុនីនោះ អស់វារៈជាគម្រប់បីដងដើម្បីឲ្យលះបង់វត្ថុនោះចេញ ។ បើភិក្ខុនីនោះ កាលត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មគម្រប់បីដង(ហើយ) លះបង់វត្ថុនោះបាន ការលះបង់បាននោះជាការល្អ បើលះបង់មិនបានទេ ភិក្ខុនីនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាយាវតតិយកគួរបណ្តេញចេញចាកសង្ឃ ។

# សង្ឃាទិសេសុទ្ទេសោ

១១- យា បន ភិក្ខុនី កិស្មិញ្ចិទេវ អធិករណេ បច្ចា កតា[១] កុបិតា អនត្តមនា ឯវំ វទេយ្យ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ទោសគាមិនិយោ ច ភិក្ខុនិយោ មោហគាមិនិយោ ច ភិក្ខុនិយោ ភយគាមិនិយោ ច ភិក្ខុនិយោតិ ។ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យេ កិស្មិញ្ចិទេវ អធិករណេ បច្ចា កតា កុបិតា អនត្តមនា ឯវំ អវច ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ទោសគាមិនិយោ ច ភិក្ខុនិយោ មោហគាមិនិយោ ច ភិក្ខុនិយោ ភយគាមិនិយោ ច ភិក្ខុនិយោតិ អយ្យា ខោ ឆន្ទាបិ គច្ឆេយ្យ ទោសាបិ គច្ឆេយ្យ មោហាបិ គច្ឆេយ្យ ភយាបិ គច្ឆេយ្យាតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

១២- ភិក្ខុនិយោ បនេវ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា ។ តា ភិក្ខុនិយោ ភិក្ខុនីហិ

(១) ក្នុងដីកា ថា បច្ចាភតា ។

# សង្ឃាទិសេសុទ្ទេស

១១- ភិក្ខុនីណាមួយ ដែលភិក្ខុនីសង្ឃធ្វើឲ្យចាញ់ ព្រោះអធិករណ៍នីមួយ ៗ ហើយខឹងអាក់អន់ចិត្ត ពោលយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីស្រឡាញ់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីស្អប់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីល្ងង់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីខ្លាចផង ។ ភិក្ខុនីនោះត្រូវភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា នែលោកម្ចាស់ លោកដែលភិក្ខុនីសង្ឃឲ្យចាញ់ ព្រោះអធិករណ៍នីមួយ ហើយខឹងអាក់អន់ចិត្ត កុំនិយាយយ៉ាងនេះថា ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីស្រឡាញ់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីស្អប់ផង ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីល្ងង់ ភិក្ខុនីទាំងឡាយលុះដោយសេចក្ដីខ្លាចផងដូច្នេះថា លោកម្ចាស់ហ្នឹងឯងលុះដោយសេចក្ដីស្រឡាញ់ខ្លះ លុះដោយសេចក្ដីស្អប់ខ្លះ លុះដោយសេចក្ដីល្ងង់ខ្លះ លុះដោយសេចក្ដីខ្លាចខ្លះ។ ភិក្ខុនីនោះ កាលដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះហើយ នៅតែប្រកាន់យ៉ាងនោះដដែល ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មដរាបដល់គម្រប់បីដង ដើម្បីឲ្យលះបង់កម្មនោះចេញ ។ ភិក្ខុនីនោះកាលបើត្រូវភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្ម ដរាបដល់គម្រប់បីដង លះបង់កម្មនោះបាន ការលះបង់បានដូច្នេះនេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេស ជាយាវតតិយកៈ គួរបណ្ដេញចេញចាកសង្ឃ ។

១២- ចំណែកភិក្ខុនីទាំងឡាយ នៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសភិក្ខុនីផងគ្នា ។ ភិក្ខុនីទាំងឡាយនោះ គួរភិក្ខុនីទាំងឡាយ

# ភិក្ខុនីបាតិមោក្ខបាលី

ឯវមស្សុ វចនីយា ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ ឯវញ្ច តា ភិក្ខុនិយោ ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យុំ តា ភិក្ខុនិយោ ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យុំ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យុំ ឥមាបិ ភិក្ខុនិយោ យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

១៣- យា បន ភិក្ខុនី ឯវំ វទេយ្យ សំសដ្ឋា វ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ សន្តិ សង្ឃេ អញ្ញាបិ ភិក្ខុនិយោ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា តា សង្ឃោ ន កិញ្ចិ អាហ តុម្ហេយេវ សង្ឃោ ឧញ្ញាយ បរិភវេន អក្ខន្តិយា វេភស្សា ទុព្វល្យា ឯវមាហ ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា

# ភិក្ខុនីបាតិមោក្ខ-ប្រែ

និយាយយ៉ាងនេះថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ នៅច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ បិទបាំងទោសភិក្ខុនីសង្ឃផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកម្ចាស់ទាំងឡាយ ចូរស្ងាត់ (ចាកពួក) សង្ឃតែងសរសើរសេចក្ដីស្ងាត់ (ចាកពួក) របស់បងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីទាំងឡាយនោះ កាលភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះហើយ ក៏នៅតែប្រកាន់ យ៉ាងនោះដដែល ភិក្ខុនីទាំងឡាយនោះ គួរភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្ម ជាគម្រប់បីដង ដើម្បីឲ្យលះបង់នូវវត្ថុនោះ ។ បើភិក្ខុនីទាំងឡាយនោះ កាលភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មជាគម្រប់បីដង លះបង់វត្ថុនោះបាន ការលះបង់បានដូច្នេះនេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីទាំងឡាយនេះក្ដី ត្រូវអាបត្តិសង្ឃាទិសេសឈ្មោះយាវតតិយកៈ គួរបណ្ដេញចេញចាកសង្ឃ ។

១៣- ភិក្ខុនីណាមួយ ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយ ចូរនៅច្រឡូកច្រឡំ ដោយគ្រហស្ថចុះ លោកទាំងឡាយ កុំនៅបែកខ្ញែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយរូបដទៃ ដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការចិញ្ចឹមជីវិតដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ សង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះ តែនឹងលោកទាំងឡាយដោយសេចក្ដីមើលងាយ ដោយពេបជ្រាយ ដោយគ្មានអំណត់ ដោយសេចក្ដីបន្ថ្លប ដោយលោកទាំងឡាយមានកម្លាំងថយថា ភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯងជាអ្នកនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់

# សង្ឃាទិសេសុទ្ទេសោ

បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យេ ឯវំ អវច សំសដ្ឋាវ អយ្យេ តុម្ហេ វិហរថ មា តុម្ហេ នានា វិហរិត្ថ សន្តិ សង្ឃេ អញ្ញាបិ ភិក្ខុនិយោ ឯវាចារា ឯវំសទ្ទា ឯវំសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា តា សង្ឃោ ន កិញ្ចិ អាហ តុម្ហេយេវ សង្ឃោ ឧញ្ញាយ បរិភវេន អក្ខន្តិយា វេភស្សា ទុព្វល្យា ឯវមាហ ភគិនិយោ ខោ សំសដ្ឋា វិហរន្តិ បាបាចារា បាបសទ្ទា បាបសិលោកា ភិក្ខុនីសង្ឃស្ស វិហេសិកា អញ្ញមញ្ញិស្សា វជ្ជប្បដិច្ឆាទិកា វិវិច្ចថយ្យេ វិវេកញ្ញេវ ភគិនីនំ សង្ឃោ វណ្ណេតីតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

# សង្ឃាទិសេសុទ្ទេស

មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់របស់ភិក្ខុនី ជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីនោះ គប្បីភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ ចូរលោកកុំនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរនៅច្រឡូកច្រឡំដោយគ្រហស្ថចុះ លោកទាំងឡាយកុំនៅបែកខ្ញែកគ្នាឡើយ សូម្បីភិក្ខុនីទាំងឡាយដទៃដែលមានមារយាទដូចគ្នា មានកិត្តិសព្ទដូចគ្នា មានការចិញ្ចឹមជីវិតដូចគ្នា ជាអ្នកបៀតបៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោស របស់ភិក្ខុនីពួកផងគ្នា មាននៅក្នុងសង្ឃដែរ សង្ឃមិនពោលពាក្យអ្វីនឹងភិក្ខុនីទាំងឡាយនោះទេ សង្ឃពោលពាក្យយ៉ាងនេះ តែនឹងលោកទាំងឡាយ ដោយសេចក្តីមើលងាយ ដោយពេបជ្រាយដោយគ្មានអំណត់ ដោយសម្តីបង្រ្គប ដោយលោកទាំងឡាយ មានកម្លាំងថយ ថាភិក្ខុនីជាបងប្អូនស្រីទាំងឡាយហ្នឹងឯង ជាអ្នកនៅច្រឡូកច្រឡំ (ដោយគ្រហស្ថ) មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀត-បៀនភិក្ខុនីសង្ឃ ជាអ្នកបិទបាំងទោសរបស់ភិក្ខុនីពួកផងគ្នា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយចូរស្ងាត់ (ចាកពួក) សង្ឃសរសើរតែសេចក្តីស្ងាត់ របស់ភិក្ខុនីជាបងប្អូនស្រីទាំងឡាយ ។ ភិក្ខុនីនោះ កាលដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ ក៏នៅតែប្រកាន់យ៉ាងនោះដដែល ភិក្ខុនីនោះគប្បីភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់នូវវត្ថុនោះដរាបដល់គម្រប់បីដង ។ បើភិក្ខុនីនោះ កាលដែលភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្ម ដរាបដល់គម្រប់បីដង លះបង់វត្ថុនោះបាន ការលះបង់បានដូច្នេះនេះជាការល្អ បើមិនលះបង់ទេ ភិក្ខុនីនេះក្តី ក៏ត្រូវអាបត្តិសង្ឃាទិសេសឈ្មោះយាវតតិយកៈ គួរបណ្តេញចេញចាកសង្ឃ ។

៤៨

# ភិក្ខុនីបាតិមោក្ខបាលី

១៤- យា បន ភិក្ខុនី សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមេយ្យ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ តិដ្ឋេយ្យ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យេ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ អដ្ឋាសិ សមេតាយ្យា សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

# ភិក្ខុនីបាតិមោក្ខ-ប្រែ

១៤- ភិក្ខុនីណាមួយ ព្យាយាមបំបែកសង្ឃ ដែលព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណ៍ ដែលនាំសង្ឃឲ្យបែកបាក់គ្នាហើយតាំងនៅ ភិក្ខុនីទាំងឡាយ ត្រូវនិយាយនឹងភិក្ខុនីនោះ យ៉ាងនេះថា លោកម្ចាស់កុំព្យាយាមបំបែកសង្ឃដែលព្រមព្រៀងគ្នាឡើយ ទាំងកុំប្រកាន់ផ្គងឡើងនូវអធិករណ៍ដែលនាំសង្ឃឲ្យបែកបាក់គ្នាហើយតាំងនៅឡើយ លោកម្ចាស់ចូរព្រមព្រៀងជាមួយនឹងសង្ឃវិញទៅ ព្រោះថាសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងតែនៅជាសុខសប្បាយ ។ កាលដែលភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះ ភិក្ខុនីនោះនៅតែប្រកាន់ ដូច្នោះដដែល ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្ម ហាមប្រាមភិក្ខុនីនោះអស់កំណត់បីដង ដើម្បីឲ្យលះបង់សង្ឃភេទកម្មនោះចេញ ។ កាលបើភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្មហាមប្រាមគ្រប់បីដងហើយ ភិក្ខុនីនោះលះបង់សង្ឃភេទកម្មនោះចេញ ការលះបង់បានដូច្នេះនេះជាការប្រពៃ បើពុំលះបង់ទេ ភិក្ខុនីនេះ ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយក គួរបណ្តេញចេញចាកសង្ឃ ។

៤៩

# សង្ឃាទិសេសុទ្ទេសោ

១៨- តស្សាយេវ ខោ បន ភិក្ខុនិយា ភិក្ខុនិយោ ហោន្តិ អនុវត្តិកា វគ្គវាទិកា ឯកា វា ទ្វេ វា តិស្សោ វា តា ឯវំ វទេយ្យុំ មាយ្យាយោ ឯតំ ភិក្ខុនឹ កិញ្ចិ អវចុត្ថ ធម្មវាទិនី ចេសា ភិក្ខុនី វិនយវាទិនី ចេសា ភិក្ខុនី អម្ហាកញ្ចេសា ភិក្ខុនី ឆន្ទញ្ច រុចិញ្ច អាទាយ វោហរតិ ជានាតិ នោ ភាសតិ អម្ហាកម្បេតំ ខមតីតិ ។ តា ភិក្ខុនិយោ ភិក្ខុនីហិ ឯវមស្សុ វចនីយា មាយ្យាយោ ឯវំ អវចុត្ថ ន ចេសា ភិក្ខុនី ធម្មវាទិនី ន ចេសា ភិក្ខុនី វិនយវាទិនី មាយ្យានម្បិ សង្ឃភេទោ រុច្ចិត្ថ សមេតាយ្យានំ សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ។ ឯវញ្ច តា ភិក្ខុនិយោ ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យុំ តា ភិក្ខុនិយោ ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យុំ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យុំ ឥមាបិ ភិក្ខុនិយោ យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

# សង្ឃាទិសេសុទ្ទេស

១៥- ភិក្ខុនីទាំងឡាយ ជាអ្នកប្រព្រឹត្តតាមភិក្ខុនី ដែលបំបែកសង្ឃនោះឯង ហើយជាអ្នកពោលប្រកាន់ពួក ទោះមួយរូបក្តី ពីររូបក្តី បីរូបក្តី ភិក្ខុនីទាំងនោះពោលហាម (ភិក្ខុនីទាំងឡាយដែលជាអ្នកបរិសុទ្ធ) យ៉ាងនេះថា សូមលោកម្ចាស់ទាំងឡាយកុំពោលពាក្យអ្វី ៗ នឹងភិក្ខុនីនេះឡើយ (ព្រោះ) ភិក្ខុនីនេះ ជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនីនេះ ជាអ្នកពោលត្រូវតាមវិន័យផង ម្យ៉ាងទៀត ភិក្ខុនីនេះកាន់យកសេចក្តីពេញចិត្តនិងសេចក្តីគាប់ចិត្តរបស់ពួកយើងទើបពោល លោកដឹងសេចក្តីពេញចិត្តជាដើមរបស់ពួកយើងទើបពោល អំពើនេះក៏គាប់ចិត្តដល់យើងទាំងឡាយ ។ ភិក្ខុនីទាំងឡាយ ត្រូវនិយាយនឹងពួកភិក្ខុនីទាំងនោះយ៉ាងនេះថា លោកម្ចាស់ទាំងឡាយកុំពោលយ៉ាងហ្នឹងឡើយ (ព្រោះ) ភិក្ខុនីនេះ មិនមែនជាអ្នកពោលត្រូវតាមធម៌ទេ ភិក្ខុនីនេះ មិនមែនជាអ្នកពោលត្រូវតាមវិន័យទេ លោកម្ចាស់ទាំងឡាយ កុំគាប់ចិត្តនឹងសង្ឃភេទឡើយ ចិត្តរបស់លោកម្ចាស់ទាំងឡាយ ចូរព្រមព្រៀងជាមួយនឹងសង្ឃវិញ ព្រោះថា សង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងតែនៅជាសុខសប្បាយ ។ កាលដែលភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះ ភិក្ខុនីទាំងនោះ នៅតែប្រកាន់ដូច្នោះដដែល ត្រូវភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមភិក្ខុនីទាំងនោះ អស់កំណាត់បីដង ដើម្បីឲ្យលះបង់អំពើនោះចេញ ។ កាលបើភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមគ្រប់បីដងហើយ ភិក្ខុនីទាំងនោះ លះបង់ អំពើនោះចេញ ការលះបង់បានដូច្នេះនុ៎ះជាការល្អ តែបើលះបង់ពុំបានទេ ភិក្ខុនីទាំងនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយក គួរបណ្តេញចេញចាកសង្ឃ ។

# ភិក្ខុនីបាតិមោក្ខបាលី

១៦- ភិក្ខុនី បនេវ ទុព្វចជាតិកា ហោតិ ឧទ្ទេសបរិយាបន្នេសុ សិក្ខាបទេសុ ភិក្ខុនីហិ សហធម្មិកំ វុច្ចមានា អត្តានំ អវចនីយំ ករោតិ មា មំ អយ្យាយោ កិញ្ចិ អវចុត្ថ កល្យាណំ វា បាបកំ វា អហម្បាយ្យាយោ ន កិញ្ចិ វក្ខាមិ កល្យាណំ វា បាបកំ វា វិរមថយ្យាយោ មម វចនាយាតិ ។ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យា អត្តានំ អវចនីយំ អកាសិ វចនីយមេវ អយ្យា អត្តានំ ករោតុ អយ្យាបិ ភិក្ខុនិយោ វទេតុ សហធម្មេន ភិក្ខុនិយោបិ អយ្យំ វក្ខន្តិ សហធម្មេន ឯវំ សំវឌ្ឍា ហិ តស្ស ភគវតោ បរិសា យទិទំ អញ្ញមញ្ញវចនេន អញ្ញមញ្ញវុដ្ឋាបនេនាតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

# ភិក្ខុនីបាតិមោក្ខ-ប្រែ

១៦- បើភិក្ខុនី មានភាពជាអ្នកដែលគេពិបាកស្តីថា កាលបើភិក្ខុនីទាំងឡាយ ពោលប្រដៅតាមធម៌ ក្នុងសិក្ខាបទទាំងឡាយ ដែលរាប់ចូលក្នុងឧទ្ទេស (បាតិមោក្ខ) ក៏ធ្វើខ្លួនឲ្យគេប្រដៅផងពុំបាន ដោយពាក្យថា សូមលោកម្ចាស់ទាំងឡាយ កុំនិយាយពាក្យអ្វីៗទោះល្អក្តី អាក្រក់ក្តី នឹងខ្ញុំឡើយ ចំណែកខ្ញុំក៏មិនពោលពាក្យអ្វីៗ ទោះល្អក្តី អាក្រក់ក្តីនឹងលោកម្ចាស់ទាំងឡាយដែរ សូមលោកម្ចាស់ទាំងឡាយ ឈប់និយាយប្រដៅខ្ញុំទៅ ។ ភិក្ខុនីទាំងឡាយ ត្រូវនិយាយនឹងភិក្ខុនីនោះយ៉ាងនេះថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេប្រដៅពុំបានដូច្នេះឡើយ លោកម្ចាស់ ចូរធ្វើខ្លួនឲ្យគេស្តីប្រដៅបានផង ចំណែកលោកម្ចាស់ ចូរនិយាយស្តី ទៅរកភិក្ខុនីទាំងឡាយតាមសហធម៌ គឺពុទ្ធប្បញ្ញត្តិ ទាំងពួកភិក្ខុនីក៏នឹងនិយាយស្តីមករកលោកម្ចាស់ តាមសហធម៌ដែរ ព្រោះថាបរិស័ទរបស់ព្រះមានព្រះភាគនោះ តែងចម្រើនឡើងដោយអាការយ៉ាងនេះ គឺដោយពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា និងដោយការញ៉ាំងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិ ។ កាលដែលភិក្ខុនីទាំងឡាយ និយាយយ៉ាងនេះ ភិក្ខុនីនោះ នៅតែប្រកាន់ដូច្នោះដដែល ត្រូវភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមភិក្ខុនីនោះអស់កំណត់បីដង ដើម្បីឲ្យលះបង់អំពើនោះចេញ ។ កាលបើភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមគ្រប់បីដងហើយ ភិក្ខុនីនោះលះបង់អំពើនោះចេញ ការលះបង់បាន ដូច្នេះនុ៎ះ ជាការល្អប្រពៃ តែបើលះបង់ពុំបានទេ ភិក្ខុនីនេះ ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយកៈ គួរបណ្តេញចេញចាកសង្ឃ ។

៦១

# សង្ឃាទិសេសុទ្ទេសោ

១៧- ភិក្ខុនី បនេវ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ កុលទូសិកា បាបសមាចារា ។ តស្សា ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ច តាយ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច ។ សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា អយ្យា ខោ កុលទូសិកា បាបសមាចារា អយ្យាយ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ចយ្យាយ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច បក្កមតយ្យា ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តា ភិក្ខុនិយោ ឯវំ វទេយ្យ ឆន្ទគាមិនិយោ ច ភិក្ខុនិយោ ទោសគាមិនិយោ ច ភិក្ខុនិយោ មោហគាមិនិយោ ច ភិក្ខុនិយោ ភយគាមិនិយោ ច ភិក្ខុនិយោ តាទិសិកាយ អាបត្តិយា ឯកច្ចំ បព្វាជេន្តិ ឯកច្ចំ ន បព្វាជេន្តីតិ ។

# សង្ឃាទិសេសសុទ្ទេស

១៧- ភិក្ខុនីចូលទៅអាស្រ័យនឹងស្រុកណាមួយ ឬនិគមណាមួយ ជាអ្នកទ្រុស្ត ត្រកូល មានការប្រព្រឹត្តអាក្រក់ ។ ការប្រព្រឹត្តអាក្រក់របស់ភិក្ខុនីនោះឯង ប្រាកដ ជាគេឃើញផង គេឮផង ទាំងត្រកូលទាំងឡាយ ដែលភិក្ខុនីទ្រុស្តហើយក៏ប្រាកដជា គេឃើញផង គេឮផង ។ ភិក្ខុនីទាំងឡាយ ត្រូវនិយាយនឹងភិក្ខុនីនោះ យ៉ាងនេះថា លោកម្ចាស់ លោកជាអ្នកទ្រុស្តត្រកូល ជាអ្នកមានការប្រព្រឹត្តអាក្រក់ពិត ការប្រព្រឹត្ត អាក្រក់របស់លោកម្ចាស់ ប្រាកដជាគេឃើញផង គេឮផង ទាំងត្រកូលទាំងឡាយ ដែលលោកម្ចាស់ទ្រុស្តហើយ ក៏ប្រាកដជាគេឃើញផង គេឮផង លោកម្ចាស់ ចូរចេញ ចាកអាវាសនេះទៅ លោកពុំគួរនឹងនៅទីនេះទេ ។ កាលដែលភិក្ខុនីទាំងឡាយ និយាយយ៉ាងនេះ ភិក្ខុនីនោះ ត្រឡប់ជាថាឲ្យភិក្ខុនីទាំងឡាយនោះ យ៉ាងនេះវិញថា ភិក្ខុនីទាំងឡាយ សុទ្ធតែលុះក្នុងក្តីស្រឡាញ់ផង ភិក្ខុនីទាំងឡាយ សុទ្ធតែលុះ ក្នុងសេចក្តីស្អប់ផង ភិក្ខុនីទាំងឡាយ សុទ្ធតែលុះក្នុងសេចក្តីលង់ខ្លៅផង ភិក្ខុនីទាំងឡាយ សុទ្ធតែលុះក្នុងសេចក្តីខ្លាចផង ព្រោះភិក្ខុនីទាំងឡាយ បណ្តេញ ភិក្ខុនីពួកខ្លះ មិនបណ្តេញភិក្ខុនីពួកខ្លះ ដោយអាបត្តិដូចតែគ្នា ។

# ភិក្ខុនីបាតិមោក្ខបាលី

សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យេ ឯវំ អវច ន ច ភិក្ខុនិយោ ឆន្ទគាមិនិយោ ន ច ភិក្ខុនិយោ ទោសគាមិនិយោ ន ច ភិក្ខុនិយោ មោហគាមិនិយោ ន ច ភិក្ខុនិយោ ភយគាមិនិយោ អយ្យា ខោ កុលទូសិកា បាបសមាចារា អយ្យាយ ខោ បាបកា សមាចារា ទិស្សន្តិ ចេវ សុយ្យន្តិ ច កុលានិ ចយ្យាយ ទុដ្ឋានិ ទិស្សន្តិ ចេវ សុយ្យន្តិ ច បក្កមតយ្យា ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ។

ឧទ្ទិដ្ឋា ខោ អយ្យាយោ សត្តរស សង្ឃាទិសេសា ធម្មា នវ បឋមាបត្តិកា អដ្ឋ យាវតតិយកា យេសំ ភិក្ខុនី អញ្ញតរំ វា អញ្ញតរំ វា អាបជ្ជតិ តាយ ភិក្ខុនិយា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ ចិណ្ណមានត្តាយ ភិក្ខុនិយា

# ភិក្ខុនីបាតិមោក្ខ-ប្រែ

ភិក្ខុនីទាំងឡាយ ត្រូវនិយាយនឹងភិក្ខុនីនោះ យ៉ាងនេះថា លោកម្ចាស់កុំនិយាយយ៉ាងនេះឡើយ ភិក្ខុនីទាំងឡាយ មិនមែនលុះក្នុងសេចក្តីស្រឡាញ់ទេ ភិក្ខុនីទាំងឡាយ មិនមែនលុះក្នុងសេចក្តីស្អប់ទេ ភិក្ខុនីទាំងឡាយ មិនមែនលុះក្នុងសេចក្តីល្ងង់ខ្លៅទេ ភិក្ខុនីទាំងឡាយមិនមែនលុះក្នុងសេចក្តីខ្លាចទេ លោកម្ចាស់ជាអ្នកទ្រុស្តត្រកូល ជាអ្នកមានការប្រព្រឹត្តអាក្រក់ពិត ការប្រព្រឹត្តអាក្រក់របស់លោកម្ចាស់ ប្រាកដជាគេឃើញផង គេឮផង ទាំងត្រកូលទាំងឡាយដែលលោកម្ចាស់ទ្រុស្តហើយ ក៏ប្រាកដជាគេឃើញផង គេឮផងដែរ លោកម្ចាស់ ចូរចេញចាកអាវាសនេះទៅ លោកពុំគួរនឹងនៅក្នុងទីនេះទេ ។ កាលដែលភិក្ខុនីទាំងឡាយពោលយ៉ាងនេះ ភិក្ខុនីនោះ នៅតែប្រកាន់ដូច្នោះដដែល ត្រូវភិក្ខុនីទាំងឡាយ សូត្រសមនុភាសនកម្ម ហាមប្រាមភិក្ខុនីនោះ អស់កំណត់បីដង ដើម្បីអោយលះបង់អំពើនោះចេញ ។ ភិក្ខុនីនោះ កាលភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មហាមប្រាម ដរាបអស់កំណត់បីដងហើយ លះបង់អំពើនោះចេញបាន ការលះបង់បានដូច្នេះនុ៎ះ ជាការប្រពៃ តែបើលះបង់ពុំបានទេ ភិក្ខុនីនេះត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះ យាវតតិយកៈ គួរបណ្តេញចេញចាកសង្ឃ ។

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិឈ្មោះសង្ឃាទិសេសទាំង ១៧ ខ្ញុំសម្តែងឡើងហើយ អាបត្តិ ៩ ឈ្មោះបឋមាបត្តិកា អាបត្តិ ៨ ឈ្មោះយាវតតិយកា បណ្តាអាបត្តិទាំង ១៧ នេះ ភិក្ខុនីអង្គណា ត្រូវអាបត្តិណា ភិក្ខុនីអង្គនោះ ត្រូវប្រព្រឹត្តបក្ខមានត្ត ក្នុងឧភតោសង្ឃ ភិក្ខុនី ប្រព្រឹត្តចិណ្ណមានត្តហើយ

# សង្ឃាទិសេសុទ្ទេសោ

យត្ថ សិយា វីសតិគណោ ភិក្ខុនីសង្ឃោ តត្ថ សា ភិក្ខុនី អព្ភេតព្វា ឯកាយបិ ចេ ឩនោ វីសតិគណោ ភិក្ខុនីសង្ឃោ តំ ភិក្ខុនឹ អព្ភេយ្យ សា ច ភិក្ខុនី អនព្ភិតា តា ច ភិក្ខុនិយោ គារយ្ហា ។ អយំ តត្ថ សាមីចិ ។ តត្ថយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

**សង្ឃាទិសេសុទ្ទេសោ និដ្ឋិតោ ។**

# សង្ឃាទិសេសុទ្ទេស

*បើភិក្ខុនីសង្ឃពួក ២០ រូប មានក្នុងទីណា ភិក្ខុនីសង្ឃត្រូវឲ្យអព្ភានកម្ម ចំពោះភិក្ខុនីនោះក្នុងទីនោះ បើភិក្ខុនីសង្ឃមិនគ្រប់ ២០ រូបទេ ខ្វះសូម្បី តែ ១ រូប ឲ្យអព្ភានកម្មចំពោះភិក្ខុនីនោះ ភិក្ខុនីនោះឈ្មោះថា ភិក្ខុនីសង្ឃមិនឲ្យអព្ភានកម្មផង ភិក្ខុនីទាំងឡាយនោះ ឈ្មោះថាត្រូវព្រះមានព្រះភាគតិះដៀលផង ។ នេះជាសាមីចិកម្ម ក្នុងរឿងនោះ ។*

*ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយ ក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំសូមសួរអស់វារៈជាគម្រប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំសូមសួរអស់វារៈជាគម្រប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងអាបត្តិទាំងនេះ ហេតុនោះទើបលោកម្ចាស់ទាំងឡាយស្ងៀម ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។*

## ចប់ សង្ឃាទិសេសុទ្ទេស ។

# ភិក្ខុនីបាតិមោក្ខបាលី

ឥមេ ខោ បនយ្យាយោ តឹស និស្សគ្គិយា បាចិត្តិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១- យា បន ភិក្ខុនី បត្តសន្និចយំ ករេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

២- យា បន ភិក្ខុនី អកាលចីវរំ កាលចីវរន្តិ អធិដ្ឋហិត្វា ភាជាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

៣- យា បន ភិក្ខុនី ភិក្ខុនិយា សទ្ធឹ ចីវរំ បរិវត្តេត្វា សា បច្ឆា ឯវំ វទេយ្យ ហន្ទយ្យេ តុយ្ហំ ចីវរំ អាហរ មេ តំ ចីវរំ យំ តុយ្ហំ តុយ្ហមេវេតំ យំ មយ្ហំ មយ្ហមេវេតំ អាហរ មេ តំ សកំ បច្ចាហរាតិ អច្ឆិន្ទេយ្យ វា អច្ឆិន្ទាបេយ្យ វា និស្សគ្គិយំ បាចិត្តិយំ ។

៤- យា បន ភិក្ខុនី អញ្ញំ វិញ្ញាបេត្វា អញ្ញំ វិញ្ញាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

៥- យា បន ភិក្ខុនី អញ្ញំ ចេតាបេត្វា អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

៦- យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

# ភិក្ខុនីបាតិមោក្ខ-ប្រែ

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិនិស្សគ្គិយបាចិត្តិយទាំងឡាយ ៣០ នេះឯង មកកាន់ឧទ្ទេស ។

១- ភិក្ខុនីណាមួយ ធ្វើសេចក្ដីសន្សំបាត្រ ភិក្ខុនីនោះត្រូវនិស្សគ្គិយបាចិត្តិយ ។

២- ភិក្ខុនីណាមួយ អធិដ្ឋានអកាលចីវរ ឲ្យជាកាលចីវរ ហើយប្រើគ្នាឲ្យចែក ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៣- ភិក្ខុនីណាមួយ ប្ដូរចីវរនឹងភិក្ខុនីផងគ្នា ហើយភិក្ខុនីនោះត្រឡប់ពោលយ៉ាងនេះ ក្នុងកាលជាខាងក្រោយថា បពិត្រលោកម្ចាស់ ណ្ហើយចុះ លោកចូរយកចីវររបស់លោកទៅវិញចុះ លោកចូរឲ្យចីវរនោះមកខ្ញុំវិញ ចីវរណារបស់លោក ចីវរនោះជារបស់លោកដដែល ចីវរណាជារបស់ខ្ញុំ ចីវរនោះជារបស់ខ្ញុំដដែលវិញ លោកចូរឲ្យចីវរនោះមកខ្ញុំ លោកចូរនាំយកចីវររបស់លោកទៅវិញចុះ ហើយដណ្ដើមយកដោយខ្លួនឯងក្ដី ប្រើគេឲ្យដណ្ដើមយកក្ដី ត្រូវនិស្សគ្គិយបាចិត្តិយ ។

៤- ភិក្ខុនីណាមួយ សុំរបស់ដទៃ ហើយសុំរបស់ឯទៀតវិញ ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៥- ភិក្ខុនីណាមួយ ឲ្យគេទិញរបស់ដទៃ ហើយត្រឡប់ឲ្យគេទិញរបស់ឯទៀតវិញ ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

៦- ភិក្ខុនីណាមួយ ឲ្យគេទិញរបស់ដទៃដោយបរិក្ខារ ដែលទាយកប្រគេនដើម្បីប្រយោជន៍វត្ថុដទៃ គេឧទ្ទិសដើម្បីវត្ថុដទៃជារបស់សង្ឃ ត្រូវនិស្សគ្គិយបាចិត្តិយ ។

# និស្សគ្គិយេ វិត្ថារុទ្ទេសោ

៧- យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន សង្ឃិកេន សញ្ញាចិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។

៨- យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។

៩- យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន មហាជនិកេន សញ្ញាចិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។

១០- យា បន ភិក្ខុនី អញ្ញទត្ថិកេន បរិក្ខារេន អញ្ញុទ្ទិសិកេន បុគ្គលិកេន សញ្ញាចិកេន អញ្ញំ ចេតាបេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។

## បត្តវគ្គោ បឋមោ

១១- គរុបាវុរណំ បន ភិក្ខុនិយា ចេតាបេន្តិយា ចតុក្កំសបរមំ ចេតាបេតព្វំ តតោ ចេ ឧត្តរឹ ចេតាបេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។

## វិត្ថារទោស ក្នុងនិស្សគ្គិយ

*៧- ភិក្ខុនីណាមួយ ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលទាយកឲ្យដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃជារបស់សង្ឃ ដោយវត្ថុដែលសូមដោយខ្លួនឯង ត្រូវនិស្សគ្គិយបាចិត្តិយ ។*

*៨- ភិក្ខុនីណាមួយ ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យ ដើម្បីប្រយោជន៍វត្ថុដទៃ ឲ្យចំពោះវត្ថុដទៃជារបស់គណៈ ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

*៩- ភិក្ខុនីណាមួយ ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់គណៈ និងដោយវត្ថុដែលសូមដោយខ្លួនឯង ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

*១០- ភិក្ខុនីណាមួយ ឲ្យគេទិញវត្ថុដទៃ ដោយបរិក្ខារដែលគេឲ្យ ដើម្បីប្រយោជន៍វត្ថុដទៃ គេឲ្យចំពោះវត្ថុដទៃ ជារបស់បុគ្គល និងដោយវត្ថុដែលសូមដោយខ្លួនឯង ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

### ចប់ បត្តវគ្គទី ១

*១១- ភិក្ខុនីកាលចាត់ចែងសំពត់ដណ្តប់ដែលមានសាច់ក្រាស់ ត្រូវចាត់ចែងបានតែសំពត់ដែលមានតម្លៃបួនកហាបណៈបួនដងយ៉ាងច្រើន បើចាត់ចែងសំពត់ដែលមានតម្លៃហួសពីនោះទៅ ត្រូវនិស្សគ្គិយបាចិត្តិយ ។*

# ភិក្ខុនីបាតិមោក្ខបាលី

១២- លហុបាវុរណំ បន ភិក្ខុនិយា ចេតាបេន្តិយា អឌ្ឍតេយ្យកំសបរមំ ចេតាបេតព្វំ តតោ ចេ ឧត្តរឹ ចេតាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

១៣- និដ្ឋិតចីវរស្មឹ ភិក្ខុនិយា ឧព្ភតស្មឹ កឋិនេ ទសាហបរមំ អតិរេកចីវរំ ធារេតព្វំ តំ អតិក្កាមេន្តិយា និស្សគ្គិយំ បាចិត្តិយំ ។

១៤- និដ្ឋិតចីវរស្មឹ ភិក្ខុនិយា ឧព្ភតស្មឹ កឋិនេ ឯករត្តម្បិ ចេ ភិក្ខុនី តិចីវរេន វិប្បវសេយ្យ អញ្ញត្រ ភិក្ខុនីសម្មតិយា និស្សគ្គិយំ បាចិត្តិយំ ។

១៥- និដ្ឋិតចីវរស្មឹ ភិក្ខុនិយា ឧព្ភតស្មឹ កឋិនេ ភិក្ខុនិយា បនេវ អកាលចីវរំ ឧប្បជ្ជេយ្យ អាកង្ខមានាយ ភិក្ខុនិយា បដិគ្គហេតព្វំ បដិគ្គហេត្វា ខិប្បមេវ ការេតព្វំ នោ ចស្ស បារិបូរិ មាសបរមំ តាយ ភិក្ខុនិយា តំ ចីវរំ និក្ខិបិតព្វំ ឩនស្ស បារិបូរិយា សតិយា បច្ចាសាយ តតោ ចេ ឧត្តរឹ និក្ខិបេយ្យ សតិយាបិ បច្ចាសាយ និស្សគ្គិយំ បាចិត្តិយំ ។

១៦- យា បន ភិក្ខុនី អញ្ញាតកំ គហបតឹ វា គហបតានឹ វា ចីវរំ វិញ្ញាបេយ្យ អញ្ញត្រ សមយា និស្សគ្គិយំ បាចិត្តិយំ ។

# ភិក្ខុនីបាតិមោក្ខ-ប្រែ

១២- ភិក្ខុនីកាលចាត់ចែងសំពត់ដណ្តប់ដែលមានសាច់ស្តើង ត្រូវចាត់ចែងបានតែសំពត់ដែលមានតម្លៃត្រឹមតែបួនកហាបណៈបីដងដោយកន្ទះ បើចាត់ចែងឲ្យហួសពីកំណត់នោះទៅ ភិក្ខុនីនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ។

១៣- កាលបើចីវរសម្រេចហើយ កឋិនដោះហើយ ភិក្ខុនីត្រូវទុកដាក់អតិរេកចីវរយ៉ាងយូរបំផុតបានត្រឹម ១០ ថ្ងៃ បើទុកឲ្យកន្លងហួសពីនោះទៅ ចីវរនោះជានិស្សគ្គិយ ភិក្ខុនីត្រូវអាបត្តិបាចិត្តិយ ។

១៤- កាលបើចីវរសម្រេចហើយ កឋិនដោះហើយ បើភិក្ខុនីនៅប្រាសចាកត្រៃ-ចីវរ សូម្បីតែមួយយប់ វៀរលែងតែភិក្ខុនីដែលបានអវិប្បវាសសម្មតិអំពីសង្ឃ ចីវរនោះជានិស្សគ្គិយ ភិក្ខុនីត្រូវអាបត្តិបាចិត្តិយ ។

១៥- កាលបើចីវរសម្រេចហើយ កឋិនដោះហើយ បើអកាលចីវរកើតឡើងដល់ភិក្ខុនី កាលបើភិក្ខុនីមានសេចក្តីត្រូវការ ក៏គប្បីទទួលចុះ លុះទទួលរួចហើយត្រូវរៀសរវៃធ្វើឲ្យឆាប់ បើសំពត់នោះខ្វះធ្វើមិនគ្រប់គ្រាន់ទេ ភិក្ខុនីនោះត្រូវទុកសំពត់នោះយ៉ាងយូរបំផុត បានត្រឹមមួយខែ បើមានបំណងថានឹងរកសំពត់ មកបំពេញចីវរខ្វះនោះ បើទុកឲ្យលើសពីមួយខែនោះទៅ បើទុកជាមានបំណងទៅទៀតក៏ដោយ ចីវរនោះជានិស្សគ្គិយ ភិក្ខុនីត្រូវអាបត្តិបាចិត្តិយ ។

១៦- ភិក្ខុនីណាមួយ សូមចីវរអំពីគហបតីក្តី អំពីគហបតានីក្តី មិនមែនជាញាតិ វៀរលែងតែមានសម័យ ចីវរនោះ ជានិស្សគ្គិយ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

៦៧

# និស្សគ្គិយេ វិត្ថារុទ្ទេសោ

តត្ថាយំ សមយោ អច្ឆិន្នចីវរា វា ហោតិ ភិក្ខុនី នដ្ឋចីវរា វា អយំ តត្ថ សមយោ ។

១៧- តញ្ចេ អញ្ញាតកោ គហបតិ វា គហបតានី វា ពហូហិ ចីវរេហិ អភិហដ្ឋុំ បវារេយ្យ សន្តរុត្តរបរមំ តាយ ភិក្ខុនិយា តតោ ចីវរំ សាទិតព្វំ តតោ ចេ ឧត្តរឹ សាទិយេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

១៨- ភិក្ខុនឹ បនេវ ឧទ្ទិស្ស អញ្ញាតកស្ស គហបតិស្ស វា គហបតានិយា វា ចីវរចេតាបនំ ឧបក្ខដំ ហោតិ ឥមិនា ចីវរចេតាបនេន ចីវរំ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុនឹ ចីវរេន អច្ឆាទេស្សាមីតិ ។ តត្រ ចេ សា ភិក្ខុនី បុព្វេ អប្បវារិតា ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ សាធុ វត មំ អាយស្មា ឥមិនា ចីវរចេតាបនេន ឯវរូបំ វា ឯវរូបំ វា ចីវរំ ចេតាបេត្វា អច្ឆាទេហីតិ កល្យាណកម្យតំ ឧបាទាយ និស្សគ្គិយំ បាចិត្តិយំ ។

១៩- ភិក្ខុនឹ បនេវ ឧទ្ទិស្ស ឧភិន្នំ អញ្ញាតកានំ គហបតីនំ វា គហបតានីនំ វា បច្ចេកចីវរចេតាបនានិ ឧបក្ខដានិ ហោន្តិ ឥមេហិ មយំ បច្ចេកចីវរចេតាបនេហិ

# វិក្តារុទ្ទេស ក្នុងនិស្សគ្គិយ

នេះជាសម័យក្នុងសិក្ខាបទនោះគឺ ភិក្ខុនីមានចីវរដែលចោរដណ្តើមយកទៅ ឬមានចីវរខូច នេះជាសម័យក្នុងសិក្ខាបទនោះ ។

១៧- បើគហបតីក្តី គហបតានីក្តី មិនមែនជាញាតិ គេបវារណាភិក្ខុនីនោះ ដើម្បីនាំយកចីវរជាច្រើនមកប្រគេន ភិក្ខុនីនោះត្រូវត្រេកអរ តែនឹងចីវរដែលមានកំណត់ យ៉ាងច្រើនបំផុត បានត្រឹមអន្តរវាសក និងឧត្តរាសង្គប៉ុណ្ណោះ អំពីចីវរដែលគេនាំមកនោះ បើត្រេកអរលើសពីកំណត់នោះទៅ ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិ បាចិត្តិយ ។

១៨- បើមានគហបតីក្តី គហបតានីក្តី មិនមែនជាញាតិ គេបម្រុងតម្លៃសម្រាប់ទិញ ចីវរ ចំពោះភិក្ខុនីថា ខ្ញុំនឹងទិញចីវរ ដោយតម្លៃចីវរនេះ ហើយឲ្យភិក្ខុនីឈ្មោះនេះ ស្លៀកដណ្តប់ចីវរ ។ បើភិក្ខុនីដែលគេមិនបវារណាជាមុននោះ ចូលទៅក្នុងទីនោះ ហើយកំណត់ចីវរ ដោយពាក្យថា ល្អហើយលោកម្ចាស់ អ្នកចូរទិញចីវរមានបែប យ៉ាងនេះៗ ដោយតម្លៃចីវរនេះហើយ ចូរឲ្យមកអាត្មាស្លៀកដណ្តប់ចុះ ព្រោះអាស្រ័យ សេចក្តីចង់បាននូវចីវរល្អ ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

១៩- បើមានតម្លៃចីវរផ្សេងគ្នា ដែលគហបតីក្តី គហបតានីក្តី ពីរនាក់មិនមែន ជាញាតិ គេឧទ្ទិសចំពោះភិក្ខុនីមួយរូបហើយ តម្កល់ទុកថា យើងនឹងទិញចីវរផ្សេងគ្នា

# ភិក្ខុនីចាតិមោក្ខចាលី

បច្ចេកចីវរានិ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុនី ចីវរេហិ អច្ឆាទេស្សាមាតិ ។ តត្រ ចេ សា ភិក្ខុនី បុព្វេ អប្បវារិតា ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ សាធុ វត មំ អាយស្មន្តោ ឥមេហិ បច្ចេកចីវរចេតាបនេហិ ឯវរូបំ វា ឯវរូបំ វា ចីវរំ ចេតាបេត្វា អច្ឆាទេថ ឧភោវ សន្តា ឯកេនាតិ កល្យាណកម្យតំ ឧបាទាយ និស្សគ្គិយំ ចាចិត្តិយំ ។

២០- ភិក្ខុនឹ បនេវ ឧទ្ទិស្ស រាជា វា រាជភោគ្គោ វា ព្រាហ្មណោ វា គហបតិកោ វា ទូតេន ចីវរចេតាបនំ បហិណេយ្យ ឥមិនា ចីវរចេតាបនេន ចីវរំ ចេតាបេត្វា ឥត្ថន្នាមំ ភិក្ខុនឹ ចីវរេន អច្ឆាទេហីតិ ។ សោ ចេ ទូតោ តំ ភិក្ខុនឹ ឧបសង្កមិត្វា ឯវំ វទេយ្យ ឥទំ ខោ អយ្យេ អយ្យំ ឧទ្ទិស្ស ចីវរចេតាបនំ អាភតំ បដិគ្គណ្ហាតុ អយ្យា ចីវរចេតាបនន្តិ ។ តាយ ភិក្ខុនិយា សោ ទូតោ ឯវមស្ស វចនីយោ ន ខោ មយំ អាវុសោ ចីវរចេតាបនំ បដិគ្គណ្ហាម ចីវរញ្ច ខោ មយំ បដិគ្គណ្ហាម កាលេន កប្បិយន្តិ ។ សោ ចេ ទូតោ តំ ភិក្ខុនឹ ឯវំ វទេយ្យ

# ភិក្ខុនីបាតិមោក្ខ-ប្រែ

ដោយតម្លៃចីវរផ្សេងគ្នាទាំងនេះហើយ នឹងឲ្យភិក្ខុនីឈ្មោះនេះ ស្លៀកដណ្តប់ចីវរទាំងឡាយ ។ បើភិក្ខុនីដែលគេមិនបានបវារណាជាមុននោះ ចូលទៅក្នុងទីនោះហើយ កំណត់ចីវរដោយពាក្យថា ល្អហើយអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងពីរចូររួបរួមគ្នាទិញចីវរបែបយ៉ាងនេះៗ ដោយតម្លៃចីវរផ្សេងគ្នាទាំងនេះហើយចូរឲ្យមកអាត្មាស្លៀកដណ្តប់ចុះ ព្រោះអាស្រ័យសេចក្តីចង់បាននូវចីវរល្អ ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

២០- ព្រះរាជាក្តី រាជអាមាត្យក្តី ព្រាហ្មណ៍ក្តី គហបតីក្តី បានឧទ្ទិសចំពោះភិក្ខុនីមួយរូប ហើយបញ្ជូនតម្លៃចីវរទៅប្រគេន តាមអ្នកបម្រើថា អ្នកឯងចូរទិញចីវរដោយតម្លៃចីវរនេះ ហើយប្រគេនភិក្ខុនីឈ្មោះនេះ ឲ្យស្លៀកដណ្តប់ចីវរ ។ បើបម្រើនោះចូលទៅរកភិក្ខុនីនោះ ហើយនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ តម្លៃចីវរនេះខ្ញុំព្រះករុណានាំមកចំពោះលោកម្ចាស់ សូមលោកម្ចាស់ទទួលយកតម្លៃចីវរចុះ ។ ទូតនោះ គឺភិក្ខុនីនោះ គប្បីពោល (ទៅកាន់) យ៉ាងនេះថា ម្នាលលោកម្ចាស់ យើងទទួលយកតម្លៃចីវរពុំបានទេ យើងទទួលយកតែចីវរដ៏សមគួរ តាមកាល ។ បើបម្រើនោះនិយាយនឹងភិក្ខុនីនោះ យ៉ាងនេះថា

៦៩

# និស្សគ្គិយេ វិត្ថារុទ្ទេសោ

អត្ថិ បនយ្យាយ កោចិ វេយ្យាវច្ចករោតិ ។ ចីវរត្ថិកាយ ភិក្ខវេ ភិក្ខុនិយា វេយ្យាវច្ចករោ និទ្ទិសិតព្វោ អារាមិកោ វា ឧបាសកោ វា ឯសោ ខោ អាវុសោ ភិក្ខុនីនំ វេយ្យាវច្ចករោតិ ។ សោ ចេ ទូតោ តំ វេយ្យាវច្ចករំ សញ្ញាបេត្វា តំ ភិក្ខុនឹ ឧបសង្កមិត្វា ឯវំ វទេយ្យ យំ ខោ អយ្យេ អយ្យា វេយ្យាវច្ចករំ និទ្ទិសិ សញ្ញត្តោ សោ មយា ឧបសង្កមតយ្យា កាលេន ចីវរេន តំ អច្ឆាទេស្សតីតិ ។ ចីវរត្ថិកាយ ភិក្ខវេ ភិក្ខុនិយា វេយ្យាវច្ចករោ ឧបសង្កមិត្វា ទ្វិត្តិក្ខត្តុំ ចោទេតព្វោ សារេតព្វោ អត្ថោ មេ អាវុសោ ចីវរេនាតិ ។ ទ្វិត្តិក្ខត្តុំ ចោទយមានា សារយមានា តំ ចីវរំ អភិនិប្ផាទេយ្យ ឥច្ចេតំ កុសលំ នោ ចេ អភិនិប្ផាទេយ្យ ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតាយ ឧទ្ទិស្ស ឋាតព្វំ ចតុក្ខត្តុំ បញ្ចក្ខត្តុំ ឆក្ខត្តុបរមំ តុណ្ហីភូតា ឧទ្ទិស្ស តិដ្ឋមានា តំ ចីវរំ អភិនិប្ផាទេយ្យ ឥច្ចេតំ កុសលំ នោ ចេ អភិនិប្ផាទេយ្យ តតោ ចេ ឧត្តរឹ វាយមមានា តំ ចីវរំ អភិនិប្ផាទេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

# វិត្ថារទោស ក្នុងនិស្សគ្គិយ

លោកម្ចាស់មានវេយ្យាវច្ចករណាមួយដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីអ្នកត្រូវការចីវរ គប្បីបង្ហាញប្រាប់វេយ្យាវច្ចករ គឺញោមវត្តឬឧបាសកថា ម្នាលអាវុសោ អ្នកនេះឯងហើយ ជាវេយ្យាវច្ចកររបស់ភិក្ខុនីទាំងឡាយ ។ បើបម្រើនោះបាននិយាយពន្យល់វេយ្យាវច្ចករនោះ ឲ្យចូលចិត្តហើយ ក៏ចូលទៅរកភិក្ខុនីនោះពោលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់បង្ហាញប្រាប់នូវវេយ្យាវច្ចករណា វេយ្យាវច្ចករនោះគឺខ្ញុំព្រះករុណា បានពន្យល់ឲ្យចូលចិត្តហើយ សូមលោកម្ចាស់ចូលទៅរកចុះ គេនឹងឲ្យលោកម្ចាស់ស្លៀកដណ្តប់ចីវរតាមកាល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីអ្នកត្រូវការចីវរ គប្បីចូលទៅតឿនទាររំឭក វេយ្យាវច្ចករពីរបីលើកថា ម្នាលអាវុសោ អាត្មាត្រូវការចីវរ ។ ភិក្ខុនីកាលទៅតឿនទាររំឭកអស់ពីរបីលើក ក៏ញុំាងចីវរនោះឲ្យសម្រេចបាន ការបានសម្រេច ដូច្នេះនុ៎ះជាការប្រពៃ បើពុំបានសម្រេចទេ ភិក្ខុនីគប្បីទៅឈរស្ងៀម ចំពោះមុខ បួនលើក ប្រាំលើក ប្រាំមួយលើកយ៉ាងច្រើន កាលបើភិក្ខុនីឈរស្ងៀម ចំពោះមុខបួនលើក ប្រាំលើក ប្រាំមួយលើក គឺយ៉ាងច្រើនបំផុតហើយ ក៏ញុំាងចីវរនោះ ឲ្យសម្រេចបាន ការសម្រេចបាន ដូចហេតុនេះនុ៎ះ ជាការប្រពៃ បើពុំបានសម្រេចទេ កាលបើភិក្ខុនីនោះ ចេះតែព្យាយាមឲ្យលើសពីកំណត់នោះ ទាល់តែបានសម្រេចចីវរនោះមក ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧០

# ភិក្ខុនីចាតិមោក្ខចាលី

នោ ចេ អភិនិច្ឆាទេយ្យ យតស្សា ចីវរចេតាបនំ អាភតំ តត្ថ សាមំ វា គន្តព្វំ ទូតោ វា ចាហេតព្វោ យំ ខោ តុម្ហេ អាយស្មន្តោ ភិក្ខុនី ឧទ្ទិស្ស ចីវរចេតាបនំ បហិណិត្ថ ន តំ តស្សា ភិក្ខុនិយា កញ្ចិ អត្ថំ អនុភោតិ យុញ្ជន្តាយស្មន្តោ សកំ មា វោ សកំ វិនស្សាតិ ។ អយំ តត្ថ សាមីចិ ។

### ចីវរវគ្គោ ទុតិយោ

២១- យា បន ភិក្ខុនី ជាតរូបរជតំ ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា ឧបនិក្ខិត្តំ វា សាទិយេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។

២២- យា បន ភិក្ខុនី នានប្បការកំ រូបិយសំវោហារំ សមាបជ្ជេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។

២៣- យា បន ភិក្ខុនី នានប្បការកំ កយវិក្កយំ សមាបជ្ជេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។

២៤- យា បន ភិក្ខុនី ឩនបញ្ចពន្ធនេន បត្តេន អញ្ញំ នវំ បត្តំ ចេតាបេយ្យ និស្សគ្គិយំ ចាចិត្តិយំ ។ តាយ ភិក្ខុនិយា សោ បត្តោ ភិក្ខុនីបរិសាយ និស្សជ្ជិតព្វោ ។ យោ ច តស្សា ភិក្ខុនីបរិសាយ បត្តបរិយន្តោ សោ តស្សា ភិក្ខុនិយា បត្តោ បទាតព្វោ អយន្តេ ភិក្ខុនិ បត្តោ យាវភេទនាយ ធារេតព្វោតិ ។ អយំ តត្ថ សាមីចិ ។

# ភិក្ខុនីបាតិមោក្ខ-ប្រែ

*បើពុំបានសម្រេចទេ បម្រើនោះនាំតម្លៃចីវរមក ដើម្បីភិក្ខុនីនោះអំពីសំណាក់អ្នកណា ភិក្ខុនីគប្បីទៅខ្លួនឯង ឬប្រើបម្រើឲ្យទៅក្នុងសំណាក់អ្នកនោះថា ម្នាលលោកម្ចាស់ទាំងឡាយ អ្នកទាំងឡាយបញ្ជូនតម្លៃចីវរទៅចំពោះភិក្ខុនីរូបណា តម្លៃចីវរនោះពុំសម្រេចប្រយោជន៍បន្តិចបន្តួច ដល់ភិក្ខុនីរូបនោះទេ អ្នកមានអាយុទាំងឡាយចូរទារយករបស់អ្នកវិញចុះ ទ្រព្យរបស់អ្នកទាំងឡាយចូរកុំវិនាសខូចឡើយ ។ នេះជាសាមីចិកម្ម គឺសេចក្តីប្រព្រឹត្តដ៏សមគួរ ក្នុងសិក្ខាបទនោះ ។*

## ចប់ ចីវរវគ្គទី ២

*២១- ភិក្ខុនីណាមួយ ទទួលខ្លួនឯងក្តី ប្រើគេឲ្យទទួលក្តី នូវមាសប្រាក់ ឬមួយត្រេកអរចំពោះមាសប្រាក់ ដែលគេទុកដាក់ឲ្យ មាសប្រាក់នោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។*

*២២- ភិក្ខុនីណាមួយ ប្រព្រឹត្តទិញដូរដោយរូបិយ មានប្រការផ្សេងៗ វត្ថុដែលទិញដូរយកមកនោះ ជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។*

*២៣- ភិក្ខុនីណាមួយ ប្រព្រឹត្តទិញដូររបស់ មានប្រការផ្សេងៗ របស់នោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។*

*២៤- ភិក្ខុនីណាមួយ មានបាត្រមានចំណងតិចជាងប្រាំ ធ្វើឲ្យគេរកបាត្រថ្មីទៀត បាត្រនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីនោះ ត្រូវលះបង់បាត្រនោះក្នុងភិក្ខុនីបរិស័ទ ។ បាត្រណាជាទីបំផុតរបស់ភិក្ខុនីបរិស័ទនោះ ភិក្ខុនីដែលសង្ឃបានសន្មត ត្រូវប្រគល់បាត្រនោះ ឲ្យដល់ភិក្ខុនីនោះដោយពាក្យថា ម្នាលភិក្ខុនី នេះជាបាត្ររបស់លោកម្ចាស់ហើយ លោកម្ចាស់ត្រូវប្រើប្រាស់ត្រាតែបែកចុះ ។ នេះជាសាមីចិកម្ម ក្នុងការលះបង់បាត្រនោះ ។*

# និស្សគ្គិយេ វិត្ថារុទ្ទេសោ

២៥- យានិ ខោ បន តានិ គិលានានំ ភិក្ខុនីនំ បដិសាយនីយានិ ភេសជ្ជានិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ ។ តានិ បដិគ្គហេត្វា សត្តាហបរមំ សន្និធិការកំ បរិភុញ្ជិតព្វានិ តំ អតិក្កាមេន្តិយា និស្សគ្គិយំ បាចិត្តិយំ ។

២៦- យា បន ភិក្ខុនី ភិក្ខុនិយា សាមំ ចីវរំ ទត្វា កុបិតា អនត្តមនា អច្ឆិន្ទេយ្យ វា អច្ឆិន្ទាបេយ្យ វា និស្សគ្គិយំ បាចិត្តិយំ ។

២៧- យា បន ភិក្ខុនី សាមំ សុត្តំ វិញ្ញាបេត្វា តន្តវាយេហិ ចីវរំ វាយាបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

២៨- ភិក្ខុនឹ បនេវ ឧទ្ទិស្ស អញ្ញាតកោ គហបតិ វា គហបតានី វា តន្តវាយេហិ ចីវរំ វាយាបេយ្យ ។ តត្រ ចេ សា ភិក្ខុនី បុព្វេ អប្បវារិតា តន្តវាយេ ឧបសង្កមិត្វា ចីវរេ វិកប្បំ អាបជ្ជេយ្យ ឥទំ ខោ អាវុសោ ចីវរំ មំ ឧទ្ទិស្ស វីយតិ អាយតញ្ច ករោថ វិត្ថតញ្ច អប្បិតញ្ច សុវីតញ្ច សុប្បវាយិតញ្ច សុវិលេខិតញ្ច សុវិតច្ឆិតញ្ច ករោថ អប្បេវ នាម មយម្បិ អាយស្មន្តានំ កិញ្ចិមត្តំ អនុប្បទជ្ជេយ្យាមាតិ ។ ឯវញ្ច សា ភិក្ខុនី វត្វា កិញ្ចិមត្តំ អនុប្បទជ្ជេយ្យ អន្តមសោ បិណ្ឌបាតមត្តម្បិ និស្សគ្គិយំ បាចិត្តិយំ ។

# វិភាគទោស ក្នុងនិស្សគ្គិយ

២៥- ភេសជ្ជៈណាមួយ ដែលពួកភិក្ខុនីមានជំងឺឆាន់បាន ភេសជ្ជៈទាំងនោះគឺ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ។ ភិក្ខុនីទទួលភេសជ្ជៈទាំងនោះហើយ គួរទុកឆាន់យ៉ាងយូរបំផុត បានត្រឹមតែប្រាំពីរថ្ងៃ បើទុកឲ្យកន្លងហួសពីនោះទៅ ភេសជ្ជៈទាំងនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៦- ភិក្ខុនីណាមួយ ឲ្យចីវរដល់ភិក្ខុនីផងគ្នា ដោយខ្លួនឯង ហើយខឹងអន់ចិត្ត ដណ្តើមយកមកវិញខ្លួនឯងក្តី ប្រើគេឲ្យដណ្តើមយកមកវិញក្តី ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៧- ភិក្ខុនីណាមួយ សូមអំបោះមកដោយខ្លួនឯង ហើយឲ្យពួកជាងតម្បាញ ត្បាញចីវរឲ្យ ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

២៨- គហបតីក្តី គហបតានីក្តី មិនមែនជាញាតិ គេឲ្យពួកជាងតម្បាញត្បាញចីវរ ចំពោះភិក្ខុនី ។ បើភិក្ខុនីនោះ ដែលអ្នកម្ចាស់ចីវរគេពុំបានបវារណាមកពីមុន ក្នុងរឿងចីវរនោះទេ អាចហ៊ានចូលទៅរកពួកជាងតម្បាញហើយ ដល់នូវកិរិយាកំណត់ក្នុងចីវរថា ម្នាលលោកម្ចាស់ទាំងឡាយ ចីវរនេះគេឲ្យត្បាញចំពោះអាត្មា អ្នកទាំងឡាយ ចូរធ្វើឲ្យវែងផង ឲ្យទូលាយផង ឲ្យមានសាច់ញឹកផង ឲ្យស្មើល្អផង រឹតឲ្យតឹងល្អផង ចូរត្រដោះកួតឲ្យល្អផង ចូរសិតឲ្យល្អផង សឹមអាត្មាថែមរង្វាន់បន្តិចបន្តួចដល់អ្នកទាំងឡាយ ។ ភិក្ខុនីនោះ លុះនិយាយយ៉ាងនេះហើយ ក៏ថែមរង្វាន់បន្តិចបន្តួចឲ្យគេ ដោយហោចទៅសូម្បីត្រឹមតែអាហារបិណ្ឌបាត ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

# ភិក្ខុនីបាតិមោក្ខបាលី

២៩- ទសាហានាគតំ កត្តិកតេមាសិបុណ្ណមំ ភិក្ខុនិយា បនេវ អច្ចេកចីវរំ ឧប្បជ្ជេយ្យ អច្ចេកំ មញ្ញមានាយ ភិក្ខុនិយា បដិគ្គហេតព្វំ បដិគ្គហេត្វា យាវ ចីវរកាលសមយំ និក្ខិបិតព្វំ តតោ ចេ ឧត្តរឹ និក្ខិបេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

៣០- យា បន ភិក្ខុនី ជានំ សង្ឃិកំ លាភំ បរិណតំ អត្តនោ បរិណាមេយ្យ និស្សគ្គិយំ បាចិត្តិយំ ។

## ជាតរូបវគ្គោ តតិយោ

ឧទ្ទិដ្ឋា ខោ អយ្យាយោ តឹស និស្សគ្គិយា បាចិត្តិយា ធម្មា ។ តត្ថាយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថាយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

## និស្សគ្គិយា បាចិត្តិយា និដ្ឋិតា ។

## ភិក្ខុនីបាតិមោក្ខ-ប្រែ

២៩- នៅខ្វះដប់ថ្ងៃទៀត នឹងដល់ថ្ងៃពេញបូណ៌មីខែកត្តិកដែលជាខែទី ៣ នៃវស្សានរដូវ បើអច្ចេកចីវរកើតដល់ភិក្ខុនី ភិក្ខុនីសម្គាល់ថា ជាអច្ចេកចីវរ គប្បីទទួលទុកបាន លុះទទួលហើយគប្បីទុកដាក់ដរាបអស់សម័យនៃចីវរកាល បើទុកឲ្យយូរហួសកំណត់នោះទៅ ចីវរនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

៣០- ភិក្ខុនីណាមួយ ដឹងហើយបង្អោនទូវលាភដែលគេប្រុងនឹងបង្អោនទៅដើម្បីសង្ឃ មកដើម្បីខ្លួនវិញ លាភនោះជានិស្សគ្គិយ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

## ចប់ជាតរូបវគ្គ ទី៣

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិឈ្មោះនិស្សគ្គិយបាចិត្តិយទាំង ៣០ ខ្ញុំព្រះករុណាបានសម្តែងរួចហើយ ខ្ញុំព្រះករុណា សូមសួរលោកម្ចាស់ទាំងឡាយក្នុងអាបត្តិទាំងនោះ លោកម្ចាស់ទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណាសូមសួរជាគម្រប់ពីរដងផង លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីដងផង លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? លោកម្ចាស់ទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធ ក្នុងអាបត្តិទាំងនោះហើយព្រោះហេតុនោះ បានជាលោកនៅស្ងៀម ខ្ញុំព្រះករុណាសូមចាំទុកនូវហេតុនេះដោយសេចក្តីនៅស្ងៀមយ៉ាងនេះ ។

**ចប់ អាបត្តិនិស្សគ្គិយបាចិត្តិយ ។**

៧៣

# ចាចិត្តិយេ វិត្ថារុទ្ទេសោ

ឥមេ ខោ បនយ្យាយោ ឆសដ្ឋិសតា ចាចិត្តិយា ជម្មា ឧទ្ទេសំ អាកច្ឆន្តិ ។

១- យា បន ភិក្ខុនី លសុណំ ខាទេយ្យ ចាចិត្តិយំ ។

២- យា បន ភិក្ខុនី សម្ពាធេ លោមំ សំហរាបេយ្យ ចាចិត្តិយំ ។

៣- តលឃាតកេ ចាចិត្តិយំ ។

៤- ជតុមដ្ឋកេ ចាចិត្តិយំ ។

៥- ឧទកសុទ្ធិកំ បន ភិក្ខុនិយា អាទិយមានាយ ទ្វង្គុលបព្វបរមំ អាទាតព្វំ តំ អតិក្កាមេន្តិយា ចាចិត្តិយំ ។

៦- យា បន ភិក្ខុនី ភិក្ខុស្ស កុញ្ជន្តស្ស ចានីយេន វា វិធូបនេន វា ឧបតិដ្ឋេយ្យ ចាចិត្តិយំ ។

៧- យា បន ភិក្ខុនី អាមកធញ្ញំ វិញ្ញាបេត្វា វា វិញ្ញាចាបេត្វា វា ភជ្ជិត្វា វា ភជ្ជាបេត្វា វា កោដ្ដេត្វា វា កោដ្ដាបេត្វា វា បចិត្វា វា បចាបេត្វា វា កុញ្ជេយ្យ ចាចិត្តិយំ ។

# វិត្ថារុទ្ទេស ក្នុងបាចិត្តិយ

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះបាចិត្តិយនេះឯង មានចំនួន ១៦៦ មកកាន់ឧទ្ទេស ។

១- ភិក្ខុនីណាមួយ ទំពាស៊ីខ្ទឹម ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

២- ភិក្ខុនីណាមួយ ឲ្យគេដករោមក្នុងទីចង្អៀត ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

៣- អាបត្តិបាចិត្តិយ មានដល់ភិក្ខុនី ព្រោះកិរិយាទះនូវផ្ទៃអង្គជាត ។

៤- អាបត្តិបាចិត្តិយ មានដល់ភិក្ខុនី ព្រោះដងបង្គូរមានសណ្ឋានរលីង ដែលគេធ្វើពីអាចម៍ល័ក្ខ ។

៥- កាលភិក្ខុនីធ្វើការជម្រះដោយទឹក ត្រូវធ្វើការជម្រះបាន ត្រឹមពីរថ្នាំងម្រាមដៃជាកំណត់ កាលឲ្យកន្ទង់ហួសពីកំណត់នោះទៅ ភិក្ខុនីនោះត្រូវអាបត្តិបាចិត្តិយ ។

៦- ភិក្ខុនីណាមួយ កាលភិក្ខុកំពុងឆាន់ ទៅបម្រើដោយទឹកក្តី ដោយផ្លិតក្តី ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

៧- ភិក្ខុនីណាមួយ សូមឯងក្តី ឲ្យគេសូមក្តី កិនឯងក្តី ឲ្យគេកិនក្តី បុកឯងក្តី ឲ្យគេបុកក្តី ចម្អិនឯងក្តី ឲ្យគេចម្អិនក្តី នូវស្រូវស្រស់ ហើយបរិភោគ ត្រូវអាបត្តិបាចិត្តិយ ។

# ភិក្ខុនីបាតិមោក្ខបាលី

៨- យា បន ភិក្ខុនី ឧច្ចារំ វា បស្សាវំ វា សង្ការំ វា វិឃាសំ វា តិរោកុឌ្ឌេ វា តិរោបាការេ វា ឆឌ្ឌេយ្យ វា ឆឌ្ឌាបេយ្យ វា បាចិត្តិយំ ។

៩- យា បន ភិក្ខុនី ឧច្ចារំ វា បស្សាវំ វា សង្ការំ វា វិឃាសំ វា ហរិតេ ឆឌ្ឌេយ្យ វា ឆឌ្ឌាបេយ្យ វា បាចិត្តិយំ ។

១០- យា បន ភិក្ខុនី នច្ចំ វា គីតំ វា វាទិតំ វា ទស្សនាយ គច្ឆេយ្យ បាចិត្តិយំ ។

## លសុណវគ្គោ បឋមោ

១១- យា បន ភិក្ខុនី រត្តន្ធការេ អប្បទីបេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា បាចិត្តិយំ ។

១២- យា បន ភិក្ខុនី បដិច្ឆន្នេ ឱកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា បាចិត្តិយំ ។

១៣- យា បន ភិក្ខុនី អជ្ឈោកាសេ បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា បាចិត្តិយំ ។

# ភិក្ខុនីបាតិមោក្ខ-ប្រែ

៨- ភិក្ខុនីណាមួយ បោលខ្លួនឯងក្តី ឲ្យគេបោលក្តី នូវឧច្ចារៈក្តី បស្សាវៈក្តី សំរាមក្តី កាកសំណល់ក្តី ទៅខាងក្រៅជញ្ជាំងក្តី ខាងក្រៅរបងក្តី ត្រូវអាបត្តិបាចិត្តិយ ។

៩- ភិក្ខុនីណាមួយ បោលខ្លួនឯងក្តី ឲ្យគេបោលក្តី នូវឧច្ចារៈក្តី បស្សាវៈក្តី សំរាមក្តី កាកសំណល់ក្តី ក្នុងទីមានវត្ថុមានពណ៌ខៀវ ត្រូវអាបត្តិបាចិត្តិយ ។

១០- ភិក្ខុនីណាមួយ ទៅដើម្បីមើលរបាំក្តី ចម្រៀងក្តី ប្រគំក្តី ត្រូវអាបត្តិបាចិត្តិយ ។

## ចប់លសុណវគ្គទី១

១១- ភិក្ខុនីណាមួយ ស្ថិតនៅក្តី និយាយក្តី តែម្នាក់និងម្នាក់មួយអន្លើដោយបុរស ក្នុងពេលយប់ងងឹតឥតមានប្រទីប ត្រូវអាបត្តិបាចិត្តិយ ។

១២- ភិក្ខុនីណាមួយ ស្ថិតនៅក្តី និយាយក្តី តែម្នាក់និងម្នាក់មួយអន្លើដោយបុរស ក្នុងទីកំបាំង ត្រូវអាបត្តិបាចិត្តិយ ។

១៣- ភិក្ខុនីណាមួយ ស្ថិតនៅក្តី និយាយក្តី តែម្នាក់និងម្នាក់មួយអន្លើដោយបុរស ក្នុងទីវាល ត្រូវអាបត្តិបាចិត្តិយ ។

៧៤

# ចាចិត្តិយេ វិត្ថារុទ្ទេសោ

១៤- យា បន ភិក្ខុនី រថិយាយ វា ព្យូហេ វា សិង្ឃាដកេ វា បុរិសេន សទ្ធឹ ឯកេនេកា សន្តិដ្ឋេយ្យ វា សល្លបេយ្យ វា និកណ្ណិកំ វា ជប្បេយ្យ ទុតិយិកំ វា ភិក្ខុនឹ ឧយ្យោជេយ្យ ចាចិត្តិយំ ។

១៥- យា បន ភិក្ខុនី បុរេភត្តំ កុលានិ ឧបសង្កមិត្វា អាសនេ និសីទិត្វា សាមិកេ អនាបុច្ឆា បក្កមេយ្យ ចាចិត្តិយំ ។

១៦- យា បន ភិក្ខុនី បច្ឆាភត្តំ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា អាសនេ អភិនិសីទេយ្យ វា អភិនិបជ្ជេយ្យ វា ចាចិត្តិយំ ។

១៧- យា បន ភិក្ខុនី វិកាលេ កុលានិ ឧបសង្កមិត្វា សាមិកេ អនាបុច្ឆា សេយ្យំ សន្ថរិត្វា វា សន្ថរាបេត្វា វា អភិនិសីទេយ្យ វា អភិនិបជ្ជេយ្យ វា ចាចិត្តិយំ ។

១៨- យា បន ភិក្ខុនី ទុគ្គហិតេន ទូបធារិតេន បរំ ឧជ្ឈាបេយ្យ ចាចិត្តិយំ ។

១៩- យា បន ភិក្ខុនី អត្តានំ វា បរំ វា និរយេន វា ព្រហ្មចរិយេន វា អភិសបេយ្យ ចាចិត្តិយំ ។

# វិភាគទោស ក្នុងបាចិត្តិយ

បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះបាដិទេសនីយ ៨ នេះ មកកាន់ឧទ្ទេស ។

១- ភិក្ខុនីណាមួយ មិនមានជំងឺ សូមសប្បិ(ទឹកដោះរាវ)ឆាន់ ភិក្ខុនីនោះ ត្រូវសម្ដែងចំពោះអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះមានព្រះភាគ តិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសម្ដែងចំពោះនូវអាបត្តិនោះ ។

២- ភិក្ខុនីណាមួយ មិនឈឺសូមប្រេងឆាន់ ភិក្ខុនីនោះ ត្រូវសម្ដែងចំពោះនូវអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះមានព្រះភាគ តិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសម្ដែងចំពោះនូវអាបត្តិនោះ ។

៣- ភិក្ខុនីណាមួយ មិនឈឺសូមមធុ(ទឹកឃ្មុំ)ឆាន់ ភិក្ខុនីនោះ ត្រូវសម្ដែងចំពោះនូវអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះមានព្រះភាគ តិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសម្ដែងចំពោះនូវអាបត្តិនោះ ។

៤- ភិក្ខុនីណាមួយ មិនឈឺសូមផាណិត(ទឹកអំពៅ)ឆាន់ ភិក្ខុនីនោះ ត្រូវសម្ដែងចំពោះ នូវអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះមានព្រះភាគ តិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសម្ដែងចំពោះនូវអាបត្តិនោះ ។

៥- ភិក្ខុនីណាមួយ មិនឈឺសូមមច្ឆា(ត្រី)ឆាន់ ភិក្ខុនីនោះ ត្រូវសម្ដែងចំពោះនូវអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះមានព្រះភាគ តិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសម្ដែងចំពោះនូវអាបត្តិនោះ ។

# ភិក្ខុនីបាតិមោក្ខបាលី

៦- យា បន ភិក្ខុនី អគិលានា មំសំ វិញ្ញាបេត្វា ភុញ្ជេយ្យ បដិទេសេតព្វំ តាយ ភិក្ខុនិយា គារយ្ហំ អយ្យេ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។

៧- យា បន ភិក្ខុនី អគិលានា ខីរំ វិញ្ញាបេត្វា ភុញ្ជេយ្យ បដិទេសេតព្វំ តាយ ភិក្ខុនិយា គារយ្ហំ អយ្យេ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។

៨- យា បន ភិក្ខុនី អគិលានា ទធឹ វិញ្ញាបេត្វា ភុញ្ជេយ្យ បដិទេសេតព្វំ តាយ ភិក្ខុនិយា គារយ្ហំ អយ្យេ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។

ឧទ្ទិដ្ឋា ខោ អយ្យាយោ អដ្ឋ បាដិទេសនីយា ធម្មា ។ តត្ថយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

**បាដិទេសនីយា និដ្ឋិតា ។**

# ភិក្ខុនីបាតិមោក្ខ-ប្រែ

*៦- ភិក្ខុនីណាមួយ មិនឈឺសូមមំសំ(សាច់)ឆាន់ ភិក្ខុនីនោះ ត្រូវសម្ដែងចំពោះនូវអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះមានព្រះភាគ តិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសម្ដែងចំពោះ នូវអាបត្តិនោះ ។*

*៧- ភិក្ខុនីណាមួយ មិនឈឺសូមខីរៈ(ទឹកដោះស្រស់)ឆាន់ ភិក្ខុនីនោះ ត្រូវសម្ដែងចំពោះ នូវអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះមានព្រះភាគ តិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសម្ដែងចំពោះ នូវអាបត្តិនោះ ។*

*៨- ភិក្ខុនីណាមួយ មិនឈឺសូមទធិ(ទឹកដោះជូរ)ឆាន់ ភិក្ខុនីនោះ ត្រូវសម្ដែងចំពោះនូវអាបត្តិនោះថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវអាបត្តិដែលព្រះមានព្រះភាគ តិះដៀលហើយ មិនជាទីសប្បាយ ឈ្មោះបាដិទេសនីយ ខ្ញុំសូមសម្ដែងចំពោះនូវអាបត្តិនោះ ។*

*បពិត្រលោកម្ចាស់ទាំងឡាយ អាបត្តិទាំងឡាយឈ្មោះបាដិទេសនីយ ៨ ខ្ញុំសម្ដែងឡើងហើយ ។ ខ្ញុំសូមសួរលោកម្ចាស់ទាំងឡាយ ក្នុងអាបត្តិទាំងនោះ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំសូមសួរអស់វារៈជាគម្រប់ពីរដងផង លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំសូមសួរអស់វារៈជាគម្រប់បីដងផង លោកម្ចាស់ទាំងឡាយ ជាអ្នកបរិសុទ្ធហើយឬ ? លោកម្ចាស់ទាំងឡាយបរិសុទ្ធ ក្នុងអាបត្តិទាំងនេះហើយ ហេតុនេះបានជាលោកនៅស្ងៀម ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។*

**ចប់ អាបត្តិបាដិទេសនីយ ។**

# សេក្ខិយេ វិត្ថារុទ្ទេសោ

ឥមេ ខោ បនយ្យាយោ សេក្ខិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

១- បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយា ។

២- បរិមណ្ឌលំ ចារុបិស្សាមីតិ សិក្ខា ករណីយា ។

៣- សុប្បដិច្ឆន្នា អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

៤- សុប្បដិច្ឆន្នា អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

៥- សុសំវុតា អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

៦- សុសំវុតា អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

៧- ឱក្ខិត្តចក្ខុនី អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

៨- ឱក្ខិត្តចក្ខុនី អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

៩- ន ឧក្ខិត្តកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

១០- ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

**បរិមណ្ឌលវគ្គោ បឋមោ**

# វិត្ថារុទ្ទេស ក្នុងសេក្ខិយ

*បពិត្រលោកម្ចាស់ទាំងឡាយ សេក្ខិយវត្តទាំងឡាយ នេះឯង មកកាន់ឧទ្ទេស ។*

*១- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងស្លៀកស្បង់ឲ្យជាបរិមណ្ឌល ។*

*២- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងគ្រងចីវរឲ្យជាបរិមណ្ឌល ។*

*៣- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងឃ្លុំឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ។*

*៤- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងឃ្លុំឲ្យល្អ អង្គុយក្នុងចន្លោះផ្ទះ ។*

*៥- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងសង្រួមឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ។*

*៦- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងសង្រួមឲ្យល្អអង្គុយក្នុងចន្លោះផ្ទះ ។*

*៧- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមានភ្នែកសម្លឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ ។*

*៨- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមានភ្នែកសម្លឹងចុះ អង្គុយក្នុងចន្លោះផ្ទះ ។*

*៩- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ ។*

*១០- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសើយចីវរ អង្គុយក្នុងចន្លោះផ្ទះ ។*

**ចប់ បរិមណ្ឌលវគ្គ ទី ១**

# ភិក្ខុនីចាតិមោក្ខបាលី

១១- ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

១២- ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

១៣- អប្បសទ្ទា អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

១៤- អប្បសទ្ទា អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

១៥- ន កាយប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

១៦- ន កាយប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

១៧- ន ពាហុប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

១៨- ន ពាហុប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

១៩- ន សីសប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

២០- ន សីសប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

## ឧជ្ជគ្ឃិកវគ្គោ ទុតិយោ

# ភិក្ខុនីបាតិមោក្ខ-ប្រែ

១១- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសើចខ្លាំង ដើរទៅក្នុង ចន្លោះផ្ទះ ។

១២- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសើចខ្លាំង អង្គុយក្នុងចន្លោះផ្ទះ ។

១៣- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងនិយាយសំឡេងតិច ដើរទៅក្នុងចន្លោះផ្ទះ ។

១៤- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងនិយាយសំឡេងតិច អង្គុយក្នុងចន្លោះផ្ទះ ។

១៥- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនគ្រលែងកាយដើរទៅ ក្នុងចន្លោះផ្ទះ ។

១៦- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនគ្រលែងកាយអង្គុយ ក្នុងចន្លោះផ្ទះ ។

១៧- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនបង់បោយដើរទៅ ក្នុងចន្លោះផ្ទះ ។

១៨- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនច្រត់ដៃអង្គុយក្នុងចន្លោះផ្ទះ ។

១៩- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនអង្រួនក្បាលដើរទៅ ក្នុងចន្លោះផ្ទះ ។

២០- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនអង្រួនក្បាលអង្គុយ ក្នុងចន្លោះផ្ទះ ។

## ចប់ ឧជ្ជគ្ឃិកវគ្គ ទី ២

# សេខិយេ វិត្ថារុទ្ទេសោ

២១- ន ខម្ភកតា អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

២២- ន ខម្ភកតា អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

២៣- ន ឱគុណ្ឋិតា អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

២៤- ន ឱគុណ្ឋិតា អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

២៥- ន ឧក្កុដិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

២៦- ន បល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

២៧- សក្កច្ចំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។

២៨- បត្តសញ្ញិនី បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។

២៩- សមសូបកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។

៣០- សមតិត្ថិកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។

## ខម្ភកតវគ្គោ តតិយោ

# វិគ្គារុទ្ទេស ក្នុងសេក្ខិយ

២១- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនយកដៃស្ទីមចង្កេះដើរទៅ ក្នុងចន្លោះផ្ទះ ។

២២- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនយកដៃស្ទីមចង្កេះ អង្គុយ ក្នុងចន្លោះផ្ទះ ។

២៣- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនទទូរក្បាល ដើរទៅ ក្នុងចន្លោះផ្ទះ ។

២៤- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនទទូរក្បាល អង្គុយ ក្នុងចន្លោះផ្ទះ ។

២៥- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនចំអើតជើង ដើរទៅក្នុងចន្លោះផ្ទះ ។

២៦- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនអង្គុយត្របោមក្បាលជង្គង់ ក្នុងចន្លោះផ្ទះ ។

២៧- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងទទួលអាហារបិណ្ឌបាត ដោយគោរព ។

២៨- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងសម្គាល់តែក្នុងបាត្រទទួលបិណ្ឌបាត ។

២៩- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងទទួលបិណ្ឌបាតឲ្យល្មមនឹងសម្ល ។

៣០- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងទទួលបិណ្ឌបាតឲ្យស្មើត្រឹមកណ្ដាប់មាត់បាត្រ ។

**ចប់ ខម្ភកតវគ្គ ទី ៣**

# ភិក្ខុនីចាតិមោក្ខចាលី

៣១- សក្កច្ចំ បិណ្ឌចាតំ កុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៣២- បត្តសញ្ញិនី បិណ្ឌចាតំ កុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៣៣- សបជានំ បិណ្ឌចាតំ កុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៣៤- សមសូបកំ បិណ្ឌចាតំ កុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៣៥- ន ថូបតោ ឱមទ្ទិត្វា បិណ្ឌចាតំ កុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៣៦- ន សូបំ វា ព្យញ្ជនំ វា ឱទនេន បជិច្ឆាទេស្សាមិ ភិយ្យោកម្យតំ ឧចាជាយាតិ សិក្ខា ករណីយា ។

៣៧- ន សូបំ វា ឱទនំ វា អក្កិលាជា អត្តជោ អត្ថាយ វិញ្ញាបេត្វា កុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៣៨- ន ឧជ្ឈានសញ្ញិនី បរេសំ បត្តំ ឱលោកេស្សាមីតិ សិក្ខា ករណីយា ។

៣៩- ជាតិមហន្តំ កពឡំ ការិស្សាមីតិ សិក្ខា ករណីយា ។

៤០- បរិមណ្ឌលំ អាលោបំ ការិស្សាមីតិ សិក្ខា ករណីយា ។

### សក្កច្ចវគ្គោ ចតុត្ថោ

# ភិក្ខុនីបាតិមោក្ខ-ប្រែ

៣១- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងឆាន់បិណ្ឌបាតដោយសេចក្ដីគោរព ។

៣២- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងសម្គាល់តែក្នុងបាត្រឆាន់បិណ្ឌបាត ។

៣៣- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងឆាន់បិណ្ឌបាតរាបឲ្យស្មើ ។

៣៤- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងឆាន់បិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល ។

៣៥- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនច្រមុះត្រង់កំពូលបាយហើយឆាន់បិណ្ឌបាត ។

៣៦- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនកកាយបាយលុបសម្លឬម្ហូប ព្រោះអាស្រ័យសេចក្ដីល្មោភច្រើន ។

៣៧- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ ឥតមានជំងឺ នឹងមិនសូមសម្ល ឬបាយដើម្បីប្រយោជន៍ខ្លួនឯង ហើយឆាន់ ។

៣៨- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនប្រុងលើកទោសហើយសម្លឹងមើលបាត្រ ពួកភិក្ខុនីដទៃ ។

៣៩- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនធ្វើពំនូតបាយឲ្យធំពេក ។

៤០- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងធ្វើពំនូតបាយ ឲ្យជាបរិមណ្ឌលគឺឲ្យមូល ។

## ចប់ សក្កច្ចវគ្គ ទី ៤

# សេខិយេ វិត្ថារុទ្ទេសោ

៤១- ន អជាហាដេ កាពឡេ មុខទ្វារំ វិវរិស្សាមីតិ សិក្ខា ករណីយា ។

៤២- ន ភុញ្ជមានា សព្វហត្ថំ មុខេ បក្ខិបិស្សាមីតិ សិក្ខា ករណីយា ។

៤៣- ន សកពឡេន មុខេន ព្យាហរិស្សាមីតិ សិក្ខា ករណីយា ។

៤៤- ន បិណ្ឌុក្ខេបកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៤៥- ន កពឡាវច្ឆេទកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៤៦- ន អវគណ្ឌការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៤៧- ន ហត្ថនិទ្ធុនកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៤៨- ន សិត្ថាវការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៤៩- ន ជិវ្ហានិច្ឆារកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៥០- ន ចបុចបុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

**កពឡវគ្គោ បញ្ចមោ**

# វិគ្គារុទ្ទេស ក្នុងសេក្ខិយ

៤១- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ កាលពំនូតបាយមិនទាន់មកដល់ នឹងមិនបើកទ្វារមាត់ចាំ ។

៤២- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ កាលឆាន់ នឹងមិនញាត់ម្រាមដៃទាំងអស់ចូលទៅក្នុងមាត់ ។

៤៣- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់ ។

៤៤- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់បោះដុំបាយទៅក្នុងមាត់ ។

៤៥- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់កាត់ពំនូតបាយ ។

៤៦- ភិក្ខុនីគប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់បៀមពំនូតបាយ ។

៤៧- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់រលាស់ដៃ ។

៤៨- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់ធ្វើគ្រាប់បាយឲ្យជ្រុះពោយពាយ ។

៤៩- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់លៀនអណ្តាត ។

៥០- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់ធ្វើសូរឲ្យឮផ្លប់ៗ ។

**ចប់ កពឡវគ្គ ទី ៥**

# ភិក្ខុនីបាតិមោក្ខបាលី

៥១- ន សុរុសុរុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៥២- ន ហត្ថនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៥៣- ន បត្តនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៥៤- ន ឱដ្ឋនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

៥៥- ន សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។

៥៦- ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេស្សាមីតិ សិក្ខា ករណីយា ។

៥៧- ន ឆត្តបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៥៨- ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៥៩- ន សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦០- ន អាវុធបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

សុរុសុរុវគ្គោ ឆដ្ឋោ

# ភិក្ខុនីបាតិមោក្ខ-ប្រែ

៥១- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់ធ្វើសូរឲ្យឮគ្រូកៗ ។

៥២- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់លិទ្ធដៃ ។

៥៣- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់លិទ្ធបាត្រ ។

៥៤- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឆាន់លិទ្ធបបូរមាត់ ។

៥៥- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ មានដៃប្រឡាក់ដោយអាមិស នឹងមិនទទួលភាជន៍ទឹកសម្រាប់ឆាន់ ។

៥៦- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនចាក់ទឹកលាងបាត្រដែលមានគ្រាប់បាយ នៅក្នុងចន្លោះផ្ទះឡើយ ។

៥៧- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ ដែលមានឆត្រនៅក្នុងដៃ ។

៥៨- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដែលមានដំបងនៅក្នុងដៃ ។

៥៩- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដែលមានគ្រឿងសស្ត្រានៅក្នុងដៃ ។

៦០- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដែលមានអាវុធនៅក្នុងដៃ ។

**ចប់ សុរុសុរុវគ្គ ទី ៦**

# សេក្ខិយេ វិត្ថារុទ្ទេសោ

៦១- ន បាទុការូឡ្ហស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦២- ន ឧបាហនារូឡ្ហស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦៣- ន យានគតស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦៤- ន សយនគតស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦៥- ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦៦- ន វេឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦៧- ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦៨- ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៦៩- ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

# វិត្ថារុទ្ទេស ក្នុងសេក្ខិយ

៦១- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដែលពាក់ទ្រនាប់ជើង ។

៦២- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដែលពាក់ស្បែកជើង ។

៦៣- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺនៅលើយាន ។

៦៤- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺនៅលើដំណេក ។

៦៥- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺអង្គុយត្របោមក្បាលជង្គង់ ។

៦៦- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺជួតក្បាល ។

៦៧- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺទទូរក្បាល ។

៦៨- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនអង្គុយផ្ទាល់លើផែនដីហើយសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈ ។

៦៩- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនអង្គុយលើអាសនៈទាបហើយសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈខ្ពស់ ។

# ភិក្ខុនីបាតិមោក្ខបាលី

៧០- ន ឋិតា និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៧១- ន បច្ឆតោ គច្ឆន្តី បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៧២- ន ឧប្បថេន គច្ឆន្តី បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

៧៣- ន ឋិតា អគិលានា ឧច្ចារំ វា បស្សាវំ វា ករិស្សាមីតិ សិក្ខា ករណីយា ។

៧៤- ន ហរិតេ អគិលានា ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។

៧៥- ន ឧទកេ អគិលានា ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។

**បាទុកាវគ្គោ សត្តមោ**

# ភិក្ខុនីបាតិមោក្ខ-ប្រែ

៧០- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនឈរសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដែលអង្គុយ ។

៧១- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនដើរខាងក្រោយ សម្ដែងធម៌ដល់មនុស្សគ្មានជំងឺដើរពីខាងមុខ ។

៧២- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញ នឹងមិនដើរក្រៅផ្លូវសម្ដែងធម៌ដល់មនុស្សគ្មានជំងឺដើរតាមផ្លូវ ។

៧៣- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញគ្មានជំងឺ នឹងមិនឈរបន្ទោបង់ឧច្ចារៈ ឬ បស្សាវៈ ។

៧៤- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញគ្មានជំងឺ នឹងមិនបន្ទោបង់ឧច្ចារៈ ឬ បស្សាវៈ ឬ ស្ដោះទឹកមាត់ លើស្មៅស្រស់ ឬ ឈើស្រស់ ។

៧៥- ភិក្ខុនី គប្បីធ្វើការសិក្សាថា អាត្មាអញគ្មានជំងឺ នឹងមិនបន្ទោបង់ឧច្ចារៈ ឬ បស្សាវៈ ឬ ស្ដោះទឹកមាត់ លើទឹក ។

## ចប់ បាទុកាវគ្គ ទី ៧

១១១

## សេក្ខិយេ វិត្ថារុទ្ទេសោ

ឧទ្ទិដ្ឋា ខោ អយ្យាយោ សេក្ខិយា ធម្មា ។ តត្ថយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

**បញ្ចសត្តតិ សេក្ខិយា និដ្ឋិតា ។**

## វិត្ថារុទ្ទេស ក្នុងសេក្ខិយ

*បពិត្រលោកម្ចាស់ទាំងឡាយ ធម៌ទាំងឡាយឈ្មោះសេក្ខិយៈ ខ្ញុំព្រះករុណា បាន សម្ដែងរួចហើយ ។ ខ្ញុំព្រះករុណា សូមសួរលោកម្ចាស់ទាំងឡាយក្នុងសេក្ខិយវត្ត ទាំង នោះ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណា សូមសួរជា គម្រប់ពីរ ដងផង លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណា សូមសួរ ជាគម្រប់ បីដងផង លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? លោកម្ចាស់ទាំងឡាយ សុទ្ធតែ ជាអ្នកបរិសុទ្ធក្នុងសេក្ខិយវត្តទាំងនុ៎ះហើយ ព្រោះហេតុនោះ បានជាលោក ស្ងៀម នៅ ។ ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។*

**ចប់ សេក្ខិយវត្ត ៧៥ ។**

១១២

# អធិករណសមថេ វិត្ថារុទ្ទេសោ

ឥមេ ខោ បនយ្យាយោ សត្ត អធិករណសមថា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

ឧប្បន្នុប្បន្នានំ អធិករណានំ សមថាយ វូបសមាយ សម្មុខាវិនយោ ទាតព្វោ សតិវិនយោ ទាតព្វោ អមូឡ្ហវិនយោ ទាតព្វោ បដិញ្ញាយ ការេតព្វំ យេភុយ្យសិកា តស្ស ចាបិយសិកា តិណវត្ថារកោតិ ។

ឧទ្ទិដ្ឋា ខោ អយ្យាយោ សត្ត អធិករណសមថា ធម្មា ។ តត្ថយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

**អធិករណសមថា និដ្ឋិតា ។**

## វិត្ថារុទ្ទេស ក្នុងអធិករណសមថ

បពិត្រលោកម្ចាស់ទាំងឡាយ ធម៌សម្រាប់រម្ងាប់អធិករណ៍ទាំងឡាយ ប្រាំពីរយ៉ាង នេះមកកាន់ឧទ្ទេស ។

ដើម្បីរម្ងាប់ ដើម្បីផ្សះផ្សា នូវអធិករណ៍ទាំងឡាយដែលកើតឡើងហើយសង្ឃ ត្រូវឲ្យសម្មុខាវិន័យ ១ សង្ឃត្រូវឲ្យសតិវិន័យ ១ សង្ឃត្រូវឲ្យអមូឡ្ហវិន័យ ១ សង្ឃ ត្រូវវិនិច្ឆ័យតាមពាក្យប្តេជ្ញារបស់ភិក្ខុនីអ្នកឆ្លើយ ១ សង្ឃត្រូវវិនិច្ឆ័យ តាមពាក្យខាងច្រើនជាប្រមាណ ១ សង្ឃត្រូវធ្វើទោសតាមកម្មរបស់ភិក្ខុនីដែលប្រព្រឹត្តលាមក ១ សង្ឃត្រូវវិនិច្ឆ័យឲ្យពួកភិក្ខុនីដែលវិវាទទាស់ទែងគ្នា លុបលាងបំបាត់ ហើយអត់អោនគ្នាទៅវិញទៅមកដូចជាគ្របមូត្រលាមកដោយស្មៅ ១ ។

បពិត្រលោកម្ចាស់ទាំងឡាយ ធម៌សម្រាប់រម្ងាប់អធិករណ៍ទាំងប្រាំពីរយ៉ាង ខ្ញុំព្រះករុណា បានសម្តែងរួចហើយ ។ ខ្ញុំព្រះករុណាសូមសួរលោកម្ចាស់ទាំងឡាយ ក្នុងធម៌ទាំងនោះ លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់ពីរដងផង លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? ខ្ញុំព្រះករុណា សូមសួរជាគម្រប់បីដងផង លោកម្ចាស់ទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ? លោកម្ចាស់ទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធក្នុងធម៌ទាំងនោះហើយ ព្រោះហេតុនោះ បានជាលោកនៅស្ងៀម ។ ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

**ចប់ អធិករណសមថ ៧ ។**

១១៣

# ឧទ្ទេសសមោធានេ វិត្ថារុទ្ទេសោ

ឧទ្ទិដ្ឋំ ខោ អយ្យាយោ និទានំ, ឧទ្ទិដ្ឋា អដ្ឋ បារាជិកា ធម្មា, ឧទ្ទិដ្ឋា សត្តរស សង្ឃាទិសេសា ធម្មា, ឧទ្ទិដ្ឋា តឹស និស្សគ្គិយា បាចិត្តិយា ធម្មា, ឧទ្ទិដ្ឋា ឆសដ្ឋិសតា បាចិត្តិយា ធម្មា, ឧទ្ទិដ្ឋា អដ្ឋ បាដិទេសនីយា ធម្មា, ឧទ្ទិដ្ឋា សេខិយា ធម្មា, ឧទ្ទិដ្ឋា សត្ត អធិករណសមថា ធម្មា ។

ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ ។ តត្ថ សព្វាហេវ សមគ្គាហិ សម្មោទមានាហិ អវិវទមានាហិ សិក្ខិតព្វន្តិ ។

## វិត្ថារុទ្ទេសោ និដ្ឋិតោ ។

## ភិក្ខុនីបាតិមោក្ខំ និដ្ឋិតំ ។

## វិគ្គាហុទ្ទេស ក្នុងការប្រជុំឧទ្ទេស

*បពិត្រលោកម្ចាស់ទាំងឡាយ និទាន ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, អាបត្តិបារាជិក ៨ ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, អាបត្តិសង្ឃាទិសេស ១៧ ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, អាបត្តិនិស្សគ្គិយបាចិត្តិយ ៣០ ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, អាបត្តិបាចិត្តិយ ១៦៦ ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, អាបត្តិបាដិទេសនីយ ៨ ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, សេក្ខិយវត្ត (៧៥) ខ្ញុំព្រះករុណា បានសម្ដែងរួចហើយ, អធិករណសមថ ៧ ខ្ញុំព្រះករុណាបាន សម្ដែងរួចហើយ ។*

*សិក្ខាបទមានប្រមាណប៉ុណ្ណេះ របស់ព្រះមានព្រះភាគអង្គនោះ មកហើយក្នុង សុត្ត: (មាតិកា) រាប់បញ្ចូលហើយក្នុងសុត្ត: មកកាន់ឧទ្ទេសរាល់កន្លះខែ ។ លោកម្ចាស់ទាំងឡាយទាំងអស់ ព្រមព្រៀងគ្នា រីករាយរកគ្នា កុំវិវាទទាស់ទែងគ្នា គប្បីសិក្សា ក្នុងសិក្ខាបទទាំងឡាយនោះ ។*

### ចប់ វិគ្គាហុទ្ទេស ។

### ចប់ ភិក្ខុនីបាតិមោក្ខ ។

# ភិក្ខុនីខន្ធកំ

(១៧៧) តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ គោតមិ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ ទុតិយម្បិ ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ គោតមិ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។

## ភិក្ខុនីខន្ធកៈ

(១៧៧) សម័យនោះ ព្រះពុទ្ធមានព្រះភាគទ្រង់គង់ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះនាងមហាបជាបតីគោតមី ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរនឹងបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ ព្រះនាងគោតមី ព្រះនាងកុំគាប់ព្រះទ័យ ឲ្យមាតុគ្រាម ចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ(នោះ)ឡើយ ។ ព្រះនាងមហាបជាបតីគោតមី បានក្រាបបង្គំទូលសូម អស់វារៈជាគម្រប់ពីរដងផងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរមាតុគ្រាមគួរនឹងបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ ព្រះនាងគោតមី ព្រះនាងកុំគាប់ព្រះទ័យ ឲ្យមាតុគ្រាម ចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ(នោះ)ឡើយ ។

# វិនយបិដកេ ចុល្លវគ្គោ

តតិយម្បិ ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ គោតមិ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ អថខោ មហាបជាបតី គោតមី ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

(១៧៨) អថខោ ភគវា កបិលវត្ថុស្មឹ យថាភិរន្តំ វិហរិត្វា យេន វេសាលី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកញ្ចរមានោ យេន វេសាលី តទវសរិ ។ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ មហាបជាបតី គោតមី កេសេ ឆេទាបេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា សម្ពហុលាហិ សាកិយានីហិ សទ្ធឹ យេន វេសាលី តេន បក្កាមិ អនុបុព្វេន យេន វេសាលី មហាវនំ កូដាគារសាលា តេនុបសង្កមិ ។ អថខោ មហាបជាបតី គោតមី សុនេហិ ចាទេហិ

# វិនយបិដក ចុល្លវគ្គ

ព្រះនាងមហាបជាបតីគោតមី បានក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈជាគម្រប់បីដងផងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរនឹងបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ ព្រះនាងគោតមី ព្រះនាងកុំគាប់ព្រះទ័យ ឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ)ឡើយ ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី បាន(ជ្រាបថា) ព្រះមានព្រះភាគមិនទ្រង់អនុញ្ញាត ឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ (ដូច្នោះ) ក៏ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ទ្រង់ព្រះកន្សែង ហើយក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចចៀសចេញទៅ ។

(១៧៨) លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងក្រុងកបិលព័ស្តុ តាមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយយាងចេញទៅកាន់ចារិកនគរវេសាលី លុះយាងទៅកាន់ចារិកដោយលំដាប់ ក៏បានទៅដល់នគរវេសាលីនោះឯង ។ មានសេចក្តីតំណាលថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះ ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី ឲ្យគេកោរព្រះកេសា ហើយស្លៀកសំពត់ជ្រលក់ ដោយទឹកអម្ចត់ ក៏ទ្រង់យាងសំដៅទៅនគរវេសាលី ចូលទៅកាន់កូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះតាមលំដាប់ ជាមួយនឹងពួកនាងសាកិយានីជាច្រើន ។ លំដាប់នោះឯង ព្រះនាងមហាបជាបតី គោតមី មានព្រះបាទទាំងពីរ ពុះពង

## ភិក្ខុនីខន្ធកេ មហាបជាបតីគោតមីវត្ថុ

រជោកិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ អដ្ឋាសិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ មហាបជាបតឹ គោតមឹ សុនេហិ បាទេហិ រជោ-កិណ្ណេន គត្តេន ទុក្ខឹ ទុម្មនំ អស្សុមុខឹ រុទមានំ ពហិទ្វា-រកោដ្ឋកេ ឋិតំ ទិស្វាន មហាបជាបតឹ គោតមឹ ឯត-ទវោច កិស្ស ត្វំ គោតមិ សុនេហិ បាទេហិ រជោកិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារ-កោដ្ឋកេ ឋិតាតិ ។ តថា ហិ បន ភន្តេ អានន្ទ ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ តេនហិ គោតមិ មុហុត្តំ ត្វំ ឥធេវ តាវ ហោហិ យាវាហំ ភគវន្តំ យាចាមិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។

# ភិក្ខុនីខន្ធកៈ  រឿងព្រះនាងមហាបជាបតីគោតមី

មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែងទៀបក្លោងទ្វារខាងក្រៅ ។ ព្រះអានន្ទដ៏មានអាយុ បានឃើញព្រះនាងមហាបជាបតីគោតមី មានព្រះបាទទាំងគូពុះពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខតូចព្រះទ័យស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែង ទៀបក្លោងទ្វារខាងក្រៅ លុះបានឃើញហើយ ក៏ពោលពាក្យនេះនឹងព្រះនាងមហាបជាបតីគោតមីថា បពិត្រព្រះនាងគោតមី ហេតុអ្វីបានជាព្រះនាង មានព្រះបាទទាំងគូពុះពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែងទៀបក្លោងទ្វារខាងក្រៅដូច្នេះ ។ ព្រះនាងមហាបជាបតីគោតមីឆ្លើយតបថា បពិត្រព្រះអានន្ទដ៏ចម្រើន បានជាដូច្នោះ ព្រោះតែព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ មកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ហើយផងសោះ ។ ព្រះអានន្ទដ៏មានអាយុ មានវាចាថា បពិត្រព្រះនាងគោតមី បើដូច្នោះ សូមព្រះនាងទ្រង់ចាំអាត្មាភាពក្នុងទីនេះមួយរំពេចសិនចុះ ទម្រាំអាត្មាភាពទៅក្រាបបង្គំទូលសុំ ព្រះមានព្រះភាគឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតជ្រាបច្បាស់ហើយ ។

# វិនយបិដកេ ចុល្លវគ្គោ

(១៧៩) អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឯសា ភន្តេ មហាបជាបតី គោតមី សុទេហិ ចាទេហិ រជោភិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ ឋិតា ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។

# វិនយបិដក ចុល្លវគ្គ

(១៧៩) លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតីគោតមីនេះ មានព្រះបាទទាំងគូពុរពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែងទៀបក្លោងទ្វារខាងក្រៅ (ព្រោះជ្រាបថា) ព្រះមានព្រះភាគមិនទ្រង់អនុញ្ញាត ឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយផង ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ ។ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគ ជាគម្រប់ពីរដងផងថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយផងចុះ ។

## ភិក្ខុនីខន្ធកេ មហាបជាបតីគោតមីវត្ថុ

អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អ-គារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ អថខោ អាយស្មា អានន្ទោ ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជំ យន្នូនាហំ អញ្ញេនបិ បរិយាយេន ភគវន្តំ យាចេយ្យំ មាតុគ្គាមស្ស តថាគត-ប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ភព្វោ នុ ខោ ភន្តេ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលំ វា

# ភិក្ខុនីខន្ធកៈ រឿងព្រះនាងមហាបជាបតីគោតមី

ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាម ចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ ។ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគ ជាគម្រប់បីដងផងថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោសឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយផងចុះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាម ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ត្រិះរិះថា ឥឡូវនេះ ព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាត ឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយទេ បើដូច្នេះ គួរតែអាត្មាអញក្រាបបង្គំទូលសូម ព្រះមានព្រះភាគ ដោយបរិយាយផ្សេងៗទៀត ដើម្បីឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន (បើ) មាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ តើអាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលខ្លះ

# វិនយបិដកេ ចុល្លវគ្គោ

សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិកាតុន្តិ ។ ភព្វា អានន្ទ មាតុគ្គាមោ តថាគតប្ប-វេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលំបិ សកទាគាមិផលំបិ អនាគាមិផលំបិ អរហត្តផលំបិ សច្ឆិកាតុន្តិ ។ សចេ ភន្តេ ភព្វា មាតុ-គ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលំបិ សកទាគាមិផលំបិ អនា-គាមិផលំបិ អរហត្តផលំបិ សច្ឆិកាតុំ ពហូបការា ភន្តេ មហាបជាបតី គោតមី ភគវតោ មាតុច្ឆា អាចាទិកា ចោ-សិកា ខីរស្ស ទាយិកា ភគវន្តំ ជនេត្តិយា កាលកតាយ ថញ្ញំ ចាយេសិ សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគត-តប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។

(១៨០) សចេ អានន្ទ មហាបជាបតី គោតមី អដ្ឋ គរុធម្មេ បដិគ្គណ្ហាតិ សា វស្សា ហោតុ ឧបសម្បទា

សកទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះ បានដែរឬទេ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ (បើ) មាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ ក៏អាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលខ្លះ សកទាគាមិផលខ្លះ អនាគាមិ-ផលខ្លះ អរហត្តផលខ្លះបាន ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើមាតុគ្រាមចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះតថាគតជ្រាបច្បាស់ហើយ អាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិ-ផលខ្លះ សកទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះ បានដែរ បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតីគោតមី មានឧបការៈច្រើន ជាព្រះមាតុច្ឆានៃព្រះមានព្រះភាគ ព្រះនាងបានទ្រាំទ្រ ថែរក្សាថ្វាយទឹកក្សីរ កាលព្រះមាតាទ្រង់ទិវង្គតទៅ ព្រះនាងបានបំបៅព្រះអង្គ (តរៀងមក) បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ជ្រាបច្បាស់ហើយផងចុះ ។

(១៨០) ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ម្នាលអានន្ទ បើព្រះនាងមហាបជាបតី គោតមី ទទួលប្រតិបត្តិ តាមគរុធម៌ទាំង ៨ បាន ឧបសម្បទានោះ ចូរសម្រេច ដល់ព្រះនាងចុះ

# ភិក្ខុនីខន្ធកេ អដ្ឋ គរុធម្មា

វស្សសតុបសម្បន្នាយ ភិក្ខុនិយា តទហុបសម្បន្នស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កាតព្វំ អយំ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ន ភិក្ខុនិយា អភិក្ខុកេ អាវាសេ វស្សំ វសិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ អន្វឌ្ឍមាសំ ភិក្ខុនិយា ភិក្ខុសង្ឃតោ ទ្វេ ធម្មា បច្ចាសីសិតព្វា ឧបោសថបុច្ឆកញ្ច ឱវាទូបសង្កមនញ្ច អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ វស្សំ វុដ្ឋាយ ភិក្ខុនិយា ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតព្វំ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ គរុធម្មំ អជ្ឈាបន្នាយ ភិក្ខុនិយា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ ឧភតោសង្ឃេ ឧបសម្បទា បរិយេសិតព្វា

# ភិក្ខុនីខន្ធកៈ គរុធម៌ ៨

(ឯគរុធម៌ ៨ នោះ) គឺ ភិក្ខុនីសូម្បីឧបសម្បទា បានមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួលធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុដែលទើបនឹងបានឧបសម្បទាក្នុងថ្ងៃនោះ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុឡើយ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរប្រការ គឺ សួរឧបោសថ ចូលទៅស្តាប់ឱវាទ អំពីសំណាក់ភិក្ខុសង្ឃរាល់កន្លះខែ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីនៅចាំវស្សារួចហើយ ត្រូវបវារណាក្នុងសំណាក់សង្ឃទាំង ២ ពួក ដោយស្ថានទាំង ៣ គឺ ឃើញក្តី ឮក្តី រង្កៀសក្តី ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្ត ក្នុងសំណាក់សង្ឃទាំង ២ ពួក ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវជួយស្វែងរកឧបសម្បទា ក្នុងសំណាក់សង្ឃទាំង ២ ពួក ដល់សិក្ខមានាដែលបានសិក្សាសិក្ខា ក្នុងធម៌ទាំង ៦ ប្រការគ្រប់ ២ ឆ្នាំ ហើយ

## វិនយបិដកេ ចុល្លវគ្គោ

អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ន ភិក្ខុនិយា កេនចិ បរិយា-យេន ភិក្ខុ អក្កោសិតព្វោ បរិភាសិតព្វោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អន-តិក្កមនីយោ អជ្ជតគ្គេ ឱវដោ ភិក្ខុនីនំ ភិក្ខូសុ វចនប-ថោ អនោវដោ ភិក្ខូនំ ភិក្ខុនីសុ វចនបថោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អ-នតិក្កមនីយោ សចេ បនានន្ទ មហាបជាបតី គោតមី ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហាតិ សា វស្សា ហោតុ ឧបសម្បទាតិ ។

(១៨១) អថខោ អាយស្មា អានន្ទោ ភគវតោ សន្តិកេ អដ្ឋ គរុធម្មេ ឧគ្គហេត្វា យេន មហាបជាបតី គោតមី តេនុបសង្កមិ ឧបសង្កមិត្វា មហាបជាបតឹ គោ-តមឹ ឯតទវោច សចេ ខោ ត្វំ គោតមិ អដ្ឋ គរុធម្មេ បដិ-គ្គណ្ហេយ្យាសិ សា វ តេ ភវិស្សតិ ឧបសម្បទា វស្សស-តុបសម្បន្នាយ ភិក្ខុនិយា តទហុបសម្បន្នស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កាតព្វំ

ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុ ដោយបរិយាយណាមួយឡើយ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ តាំងពីថ្ងៃ (ដែលបានឧបសម្បទានេះទៅ) ភិក្ខុនីត្រូវតែស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញទេ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ម្នាលអានន្ទ បើព្រះនាងមហាបជាបតីគោតមី ទទួលប្រតិបត្តិតាមគរុធម៌ទាំង ៨ នេះបាន ឧបសម្បទានោះ ចូរសម្រេច ដល់ព្រះនាងចុះ ។

(១៨១) លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានរៀនគរុធម៌ទាំង ៨ ក្នុងសំណាក់ព្រះមានព្រះភាគ (ចាំស្ទាត់ហើយ) ក៏ចូលទៅរកព្រះនាងមហាបជាបតី គោតមី លុះចូលទៅដល់ហើយ ពោលពាក្យនេះនឹងព្រះនាងមហាបជាបតី គោតមីថា បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិ តាមគរុធម៌ទាំង ៨ បាន ឧបសម្បទានោះ ទើបបានសម្រេចដល់ព្រះនាង (ឯគរុធម៌ទាំង ៨ នោះ គឺ) ភិក្ខុនីសូម្បីបានឧបសម្បទា មួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុ ដែលទើបនឹងបួស ក្នុងថ្ងៃនោះ

# ភិក្ខុនីខន្ធកេ អដ្ឋ គរុធម្មា

អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ន ភិក្ខុនិយា អភិក្ខុកេ អាវា-សេ វស្សំ វសិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ អន្វឌ្ឍមាសំ ភិក្ខុនិយា ភិក្ខុសង្ឃតោ ទ្វេ ធម្មា បច្ចាសីសិតព្វា ឧបោសថបុច្ឆកញ្ច ឱវាទុបសង្កមនញ្ច អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្ក-មនីយោ វស្សំ វុដ្ឋាយ ភិក្ខុនិយា ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតព្វំ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ គរុធម្មំ អជ្ឈាបន្នាយ ភិក្ខុនិ-យា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្ក-មនីយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ ឧភតោសង្ឃេ ឧបសម្បទា បរិយេសិ-តព្វា អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ន ភិក្ខុនិយា

# ភិក្ខុនីខន្ធកៈ គរុធម៌ ៨

ធម៌នេះ ភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាប អស់ជីវិត ១ ភិក្ខុនីមិនត្រូវនៅចាំវស្សា ក្នុងអាវាសដែលគ្មានភិក្ខុទេ ធម៌នេះភិក្ខុនី ត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនី ត្រូវប្រាថ្នាធម៌ពីរប្រការ គឺ សួរបាតិមោក្ខ ចូលទៅស្តាប់ឱវាទ អំពីសំ- ណាក់ភិក្ខុសង្ឃរាល់កន្លះខែ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីនៅចាំវស្សារួចហើយ ត្រូវ បវារណាក្នុងសំណាក់សង្ឃទាំង ២ ពួក ដោយស្ថានទាំង ៣ គឺឃើញក្តី ឮក្តី រង្កៀសក្តី ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រ- ព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខ- មានត្តក្នុងសំណាក់សង្ឃទាំង ២ ពួក ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវជួយស្វែង រកឧបសម្បទា ក្នុងសំណាក់សង្ឃទាំង ២ ពួក ដល់សិក្ខមានាដែលបាន សិក្សាសិក្ខាក្នុងធម៌ទាំង ៦ ប្រការគ្រប់ ២ ឆ្នាំហើយ ធម៌នេះភិក្ខុនីត្រូវធ្វើ សក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនី

កេនចិ បរិយាយេន ភិក្ខុ អក្កោសិតព្វោ បរិភាសិតព្វោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ អជ្ជតគ្គេ ឱវដោ ភិក្ខុនីនំ ភិក្ខូសុ វចនបថោ អនោវដោ ភិក្ខូនំ ភិក្ខុនីសុ វចនបថោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ សចេ ខោ ត្វំ គោតមិ ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហេយ្យាសិ សាវ តេ ភវិស្សតិ ឧបសម្បទាតិ ។ សេយ្យថាបិ ភន្តេ អានន្ទ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនជាតិកោ សីសំ ន្ហាតោ ឧប្បលមាលំ វា វស្សិកមាលំ វា អធិមត្តកមាលំ វា[១] លភិត្វា ឧភោហិ ហត្ថេហិ បដិគ្គហេត្វា ឧត្តមង្គេ សិរសិ បតិដ្ឋាបេយ្យ ឯវមេវ ខោ អហំ ភន្តេ អានន្ទ ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហាមិ យាវជីវំ អនតិក្កមនីយេតិ ។

(១៨២) អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

---

១ ឱ. ម. អតិមុត្តកមាលំ វា ។

## វិនយបិដក ចុល្លវគ្គ

មិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុ ដោយបរិយាយណាមួយឡើយ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ តាំងពីថ្ងៃ (ដែលបានឧបសម្បទានេះទៅ) ភិក្ខុនីត្រូវស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញទេ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រព្រឹត្តគរុធម៌ទាំង ៨ នេះបាន ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាងមិនខាន ។ ព្រះនាងមហាបជាបតីគោតមីឆ្លើយតបថា បពិត្រព្រះអានន្ទដ៏ចម្រើន ស្រ្តីឬបុរសនៅក្រមុំកំលោះ តែងចូលចិត្តស្អិតស្អាងខ្លួន សិតសក់ស្អាតហើយ បានកម្រងផ្កាឧប្បលក្តី ផ្កាម្លិះក្តី ផ្កាដែលមានក្លិនក្រអូបណាស់ក្តី ហើយទទួលយកដោយដៃទាំងពីរ តម្កល់ទុកលើអវយវៈដ៏ឧត្តម គឺត្បូង យ៉ាងណាមិញ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំនឹងទទួលប្រតិបត្តិតាមគរុធម៌ទាំង ៨ នេះ (ដោយសេចក្តីពេញចិត្ត) ហើយមិនប្រព្រឹត្តកន្លង ដរាបអស់ជីវិត ដូច្នោះដែរ ។

(១៨២) លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ

## ភិក្ខុនីខន្ធកំ ព្រហ្មចរិយំ អចិរដ្ឋិតិកំ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច បដិគ្គហិតា ភន្តេ មហាបជាបតិយា គោតមិយា អដ្ឋ គរុធម្មា ឧបសម្បន្នា ភគវតោ មាតុច្ឆាតិ[១] ។ សចេ បនានន្ទ[២] នាលភិស្ស មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជំ ចិរដ្ឋិតិកំ អានន្ទ ព្រហ្មចរិយំ អភវិស្ស វស្សសហស្សំ សទ្ធម្មោ តិដ្ឋេយ្យ យតោ ច ខោ អានន្ទ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិតោ នទានិ អានន្ទ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ភវិស្សតិ[៣] បញ្ចេវទានិ អានន្ទ វស្សសតានិ សទ្ធម្មោ ឋស្សតិ សេយ្យថាបិ អានន្ទ យានិ កានិចិ កុលានិ ពហុឥត្ថិកានិ[៤] អប្បបុរិសកានិ តានិ សុប្បធំសិយានិ ហោន្តិ ចោរេហិ កុម្ភថេនកេហិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ

---

១ មាតុច្ឆាយាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ម. សចេ អានន្ទ ។ ៣ ឯត្ថន្តរេ នទានិ អានន្ទ វស្សសហស្សានិ សទ្ធម្មោ តិដ្ឋេយ្យាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៤ ឱ. ម. ពហុត្ថិកានិ ។

## ភិក្ខុនីខន្ធកៈ ព្រហ្មចារ្យមិនបានតាំងនៅយូរអង្វែង

ហើយគង់ក្នុងទីដ៏សមគួរ ។ ព្រះអានន្ទមានអាយុ លុះគង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន គរុធម៌ទាំង ៨ យ៉ាង ព្រះនាងមហាបជាបតីគោតមី បានទទួលហើយ ព្រះមាតុច្ឆានៃព្រះមានព្រះភាគ បានឧបសម្បទារួចហើយ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ បើប្រសិនណាជាមាតុគ្រាម មិនបានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយទេ ម្នាលអានន្ទ ព្រហ្មចារ្យនឹងបានតាំងនៅជាអង្វែង ព្រះសទ្ធម្មគឺអរហត្តផល ក៏នឹងបានតាំងនៅអស់ ១ ពាន់ឆ្នាំ ម្នាលអានន្ទ តែកាលណាមាតុគ្រាមចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ ម្នាលអានន្ទ ឥឡូវនេះ ព្រហ្មចារ្យមិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ឥឡូវនេះ ព្រះសទ្ធម្មនឹងឋិតនៅបានត្រឹមតែប្រាំរយឆ្នាំវិញ ម្នាលអានន្ទ មាតុគ្រាមបានចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិ-ន័យគឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ប្រៀបដូចត្រកូលទាំងឡាយណានីមួយ ដែលមានស្ត្រីច្រើន មានប្រុសតិច ត្រកូលទាំងនោះ ពួកចោរលួចក្អមឆ្នាំង ក៏អាចចូលមកបំផ្លាញបានដោយងាយ ម្នាលអានន្ទ មាតុគ្រាមបានចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ គឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនតាំងនៅយូរអង្វែងទេ

ហោតិ សេយ្យថាបិ អានន្ទ សម្បន្នេ សាលិក្ខេត្តេ សេតដ្ឋិកា នាម រោគជាតិ និបតតិ ឯវំ តំ សាលិក្ខេត្តំ ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ហោតិ សេយ្យថាបិ អានន្ទ សម្បន្នេ ឧច្ឆុក្ខេត្តេ មញ្ជេដ្ឋិកា នាម រោគជាតិ និបតតិ ឯវំ តំ ឧច្ឆុក្ខេត្តំ ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ហោតិ សេយ្យថាបិ អានន្ទ បុរិសោ មហតោ តឡាកស្ស បដិកច្ចេវ ចាឡឹ[១] ពន្ធេយ្យ យាវទេវ ឧទកស្ស អនតិក្កមនាយ ឯវមេវ ខោ អានន្ទ មយា បដិកច្ចេវ ភិក្ខុនីនំ អដ្ឋ គរុធម្មា បញ្ញត្តា យាវជីវំ អនតិក្កមនីយាតិ ។

**ភិក្ខុនីនំ អដ្ឋ គរុធម្មា និដ្ឋិតា ។**

---

១ ឱ. ម. អាឡឹ ។

# វិនយបិដក ចុល្លវគ្គ

ម្នាលអានន្ទ ប្រៀបដូចជារោគជាតិ ឈ្មោះសេតដ្ឋិកា (គ្រាវ) ធ្លាក់ចុះក្នុងស្រែស្រូវណា ដែលកំពុងតែលូតលាស់ល្អ ស្រែស្រូវនោះ មិនបានតាំងនៅយូរអង្វែង ដោយប្រការដូច្នេះ ម្នាលអានន្ទ មាតុគ្រាម បានចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ គឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ប្រៀបដូចរោគជាតិឈ្មោះមញ្ជេដ្ឋិកា (ជង្គ័វគ្រាវ) ធ្លាក់ចុះ ក្នុងច្បារអំពៅណា ដែលកំពុងតែលូតលាស់ល្អ ច្បារអំពៅនោះ មិនបានតាំងនៅអង្វែង ដោយប្រការដូច្នេះ ម្នាលអានន្ទ គរុធម៌ ៨ ប្រការ ដែលតថាគតបានបញ្ញត្តហើយ ចំពោះភិក្ខុនីជាដំបូង ដើម្បីមិនឲ្យ (ភិក្ខុនី) ប្រព្រឹត្តកន្លងជរាបដល់អស់ជីវិត ម្នាលអានន្ទ ប្រៀបដូចជាបុរសប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំ ដើម្បីនឹងទប់ទឹកមិនឲ្យហូរចេញទៅជាជរាប ។

**ចប់ គរុធម៌ទាំង ៨ របស់ពួកភិក្ខុនី ។**

## រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

## គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅភិក្ខុនីបាតិមោក្ខបាលី និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក

សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី

សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា

សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ


វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org